ក

# មាតិកា

## I_ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រម


០២-៨-២០១០ -ព្រះរាជក្រម នស/រកម/០៨១០/០១៤ ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋាភិបាល នៃរដ្ឋជាសមាជិក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋកូរ៉េ ៦៣៧១


### ២_ព្រះរាជក្រឹត្យ


២៨-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៥២១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យូ សាង** (YOO SANG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **យូ សំណាង** (YOO SAM NANG) ៦៤៤៦

២៨-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៥២២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជុង សឹងបេ** (JUNG SEUNG BAE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតនៅ សាធារណរដ្ឋកូរ៉េ ៦៤៤៧

២៨-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៥៣០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ជូនលោក **អាសីឌីន បេសឆាអ៊ូជ** (AZEDINE BESCHAOUCH) ជនជាតិទុយនីស៊ី សញ្ជាតិទុយនីស៊ី កើតនៅក្រុងទុយនីស៊ី ប្រទេសទុយនីស៊ី ៦៤៤៨

៣០-៦-២០១០ -ព្រះរាជក្រឹត្យ នស/រកត/០៦១០/៥៣៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **មូន ចូសេហ្វ ជី.អេល** (MOONS JOZEF J.L ) ជនជាតិបែលហ្ស៊ិក សញ្ជាតិបែលហ្ស៊ិក កើតនៅ ទីក្រុងធូនហ៊ាក ប្រទេសបែលហ្ស៊ិក ៦៤៤៩


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


០៣-៨-២០១០ -អនុក្រឹត្យលេខ ៨៣ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ៦៤៥០

០៣-៨-២០១០ -អនុក្រឹត្យលេខ ៨៤ អនក្រ.បក ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ៦៤៥៨

២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៨៣ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៦៤៦៦
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៨៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៤៦៨
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៨៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៤៦៩
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៨៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមប្រែសណីយ៍កម្ពុជា ៦៤៧០
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៨៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៤៧២
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៨៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៣
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៨៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៤៧៤
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៩០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៤៧៥
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៩១ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៦
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៩២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៤៧៧
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៩៣ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦៤៧៨
២៣-៧-២០១០ -អនុក្រឹត្យលេខ ៧៩៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៦៤៧៩

## ២.សេចក្តីសម្រេច

០៥-៨-២០១០ -សេចក្តីសម្រេចលេខ ៣៩ សសរ ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៦៤៨១

## III.ការងារបណ្តាក្រសួង

### ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២៦-៧-២០១០ -ប្រកាសលេខ ៦១២ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន សាន់ វែល ស៊ូ បង្កើតរោងចក្រ ផលិតស្បែកជើង ៦៤៨២
២៦-៧-២០១០ -ប្រកាសលេខ ៦១៣ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ឌី វីន (ខេមបូឌា) អ៊ិនដាស្ទ្រី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៦៤៨៦
២៦-៧-២០១០ -ប្រកាសលេខ ៦១៤ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ៊ី-យាន អ៊ិនធើណេសិនណល ខប បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ និង ប៉ាក់ ៦៤៩០

### ២.ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

០៣-៨-២០១០ -ប្រកាសលេខ ៣៩៣ ប្រក.សក/គណក ស្តីពី តួនាទី និង ភារកិច្ច របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និង គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យ យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ៦៤៩៤

# ព្រះរាជក្រម

នស/រកម/០៧១០/០១៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL — ព្រះបរមរាជវាំង

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ច ព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ទូលំទូលាយរវាងរដ្ឋាភិបាលនៃរដ្ឋជាសមាជិក សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ ដែលបានចុះហត្ថលេខានៅទីក្រុងចេជូ-ដូ សាធារណរដ្ឋកូរ៉េ នាថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៩ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១០

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.រកម.០៨១០.០១៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

2/2

លេខ: ៥៩០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុំ ប៊ិនគេន

# កិច្ចព្រមព្រៀងវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋ កូរ៉េ

រដ្ឋាភិបាលប្រទេសប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋ ហ្វីលីពីន សាធារណរដ្ឋសឹង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ សាធារណរដ្ឋសង្គមនិយមវៀតណាម ជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋ កូរ៉េ :

**រំលឹកឡើងវិញនូវ** កិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងរដ្ឋាភិបាលនៃបណ្តាប្រទេស ជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋកូរ៉េ (តទៅហៅថា កិច្ចព្រមព្រៀងក្របខ័ណ្ឌ) ដែលបាន ចុះហត្ថលេខានៅទីក្រុងកូឡាឡាំពូរនៃប្រទេស ម៉ាឡេស៊ី នាថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ២០០៥ ។

**រំលឹកបន្ថែមទៀត** នៅក្នុងមាត្រា ១.៣ និង ២.3 នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌដែលឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់បណ្តារដ្ឋភាគីទាំងអស់ ដើម្បីស្ថាបនាតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េដែលគ្របដណ្តប់ការវិនិយោគ ។

**បញ្ជាក់អះអាងឡើងវិញនូវ** ការប្តេជ្ញាចិត្តរបស់បណ្តាភាគីទាំងអស់ ដើម្បីបង្កើតរបបវិនិយោគមួយដែលមានលក្ខណៈសេរី មានកិច្ចសំរួល មានតម្លាភាព និងមានភាពប្រកួតប្រជែង សំដៅឆ្ពោះទៅសំរេចឱ្យបាននូវបរិស្ថានធុរកិច្ចមួយប្រកបដោយមិត្តភាព ក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េ ដោយផ្តល់នូវកិច្ចការពារដល់ អ្នកវិនិយោគនៃភាគីទាំងអស់ ក៏ដូចជា ការវិនិយោគរបស់គេ ក្រោមរបបវិនិយោគ ។

**ទទួលស្គាល់** ការធ្វើឱ្យប្រសើរឡើងនូវកាលានុវត្តភាពរវាងគ្នាទៅវិញទៅមក និងជួយបង្កើននូវលំហូរទុនវិនិយោគពីផ្នែកឯកជន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៃបណ្តាប្រទេសជាសមាជិកអាស៊ាន និងសាធារណរដ្ឋកូរ៉េ ។

**កត់សំគាល់ឃើញអំពី** ដំណាក់កាលខុសៗគ្នានៃការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន និងតម្រូវឱ្យមានភាពបត់បែន ដើម្បីផ្តល់ឱ្យប្រទេសជាសមាជិកអាស៊ានថ្មី ជាពិសេសនូវតម្រូវការសំរបសំរួលដល់ ការនៃកើនឡើងនៃការ ចូលរួមរបស់ភាគីទាំងអស់ ក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពង្រីកការនាំចេញរបស់គេ រួមបញ្ចូលទាំង ការពង្រឹងសមត្ថភាពក្នុងស្រុករបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងមានការប្រកួតប្រជែង ។

**ភាគីទាំងឡាយបានព្រមព្រៀងគ្នាតាមខ្លឹមសារដូចខាងក្រោម :**

## មាត្រា ១
## និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

(ក) **ប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍** មានន័យថា ប្រទេសប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយឡែក១ពីគ្នា ។

(ខ) **បណ្តាប្រទេសជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍** មានន័យថា ប្រទេសប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម រួមគ្នា ។

(គ) **ដែនវិនិយោគ** មានន័យថា ការវិនិយោគក្នុងដែនដីនៃភាគីមួយរបស់អ្នកវិនិយោគនៃភាគីមួយទៀត ដែលមានស្រាប់ គិតត្រឹមកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ឬដែលបានបង្កើតឡើង បានទិញយក ឬបានពង្រីកក្រោយពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងដែលត្រូវបានអនុញ្ញាតស្របតាមច្បាប់ បទបញ្ញត្តិ និងគោលនយោបាយជាតិក្នុងស្រុករបស់ខ្លួន ហើយត្រូវបានការអនុម័តយល់ព្រមជាក់លាក់ជាលាយលក្ខណ៍អក្សរ[១] ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនតាមការដែលអាចអនុវត្តបាន ។

(ឃ) **ភាគីមានវិវាទទាំងអស់** មានន័យថា អ្នកវិនិយោគមានវិវាទ និងភាគីមួយដែលមានវិវាទ ។

(ង) **ភាគីមានវិវាទណាមួយ** មានន័យថា ភាគីមួយប្រឈមនឹងបណ្តឹងទាមទារដែលត្រូវបានធ្វើឡើងនៅក្រោមមាត្រា១៨ (ដំណោះស្រាយវិវាទវិនិយោគ រវាងភាគីមួយ និងអ្នកវិនិយោគរបស់ភាគីមួយផ្សេងទៀត) ។

---

[១] សំរាប់គោលបំណងនៃកិច្ចការពារនានា នីតិវិធីដែលបានអនុម័តជាក់លាក់ជាលាយលក្ខណ៍អក្សរ ត្រូវបានកំណត់ដូចមានចែងក្នុងឧបសម្ព័ន្ធ១ (អនុម័តជាលាយលក្ខណ៍អក្សរ) ។

(ច) **កិច្ចព្រមព្រៀងក្របខ័ណ្ឌ** មានន័យថា កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋាភិបាលនៃបណ្តាប្រទេសជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង សាធារណរដ្ឋ កូរ៉េ ។

(ឆ) **រូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី** មានន័យថា គ្រប់រូបិយប័ណ្ណដែលបានកំណត់ដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមមាត្រានៃកិច្ចព្រមព្រៀងរបស់ខ្លួន និងវិសោធនកម្មនានាដែលមានក្នុងនោះ ។

(ជ) GATS មានន័យថាកិច្ចព្រមព្រៀងពាណិជ្ជកម្មទូទៅលើសេវាកម្មដូចមានចែងក្នុងឧបសម្ព័ន្ធ ១ (ខ) នៃកិច្ចព្រមព្រៀងរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ។

(ឈ) **គណៈកម្មាធិការប្រតិបត្តិ** មានន័យថា គណៈកម្មាធិការបង្កើតឡើងក្រោមមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ។

(ញ) **ការវិនិយោគ** មានន័យថា ទ្រព្យសម្បត្តិគ្រប់ប្រភេទដែលជាកម្មសិទ្ធិ ឬត្រួតត្រាដោយអ្នកវិនិយោគ និងមានលក្ខណៈវិនិយោគ ដូចជា កិច្ចសន្យាផ្តល់មូលធន ឬប្រភពធនធានផ្សេងទៀត ការរំពឹងទុកនៃផលចំណូល ឬប្រាក់ចំណេញ ឬការសន្មតជាមុននូវហានិភ័យ និងជាពិសេស ដោយរាប់បញ្ចូល ប៉ុន្តែមិនកំណត់ត្រឹមទ្រព្យសម្បត្តិដូចខាងក្រោមនេះទេ :

(i) ចលនទ្រព្យ និងអចលនទ្រព្យ និងសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀតដូចជាទ្រព្យដាក់បញ្ចាំ ប្រាតិភោគបំណុល (វត្ថុដាក់ធានាបំណុល) ឬប្រាក់សន្យាផ្តល់ឱ្យ។

(ii) ភាគហ៊ុន ហ៊ុន និងប័ណ្ណបំណុល នៃនីតិបុគ្គល ឬផលប្រយោជន៍ លើទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ។

(iii) កម្មសិទ្ធិបញ្ញាដែលត្រូវបានទទួលស្គាល់ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិនៃភាគីម្ចាស់ផ្ទះ និងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលភាគីម្ចាស់ផ្ទះជាភាគីមួយ និងដោយសុឆន្ទៈ ។

(iv) សម្បទានពាណិជ្ជកម្ម[២] ដែលបានផ្តល់ឱ្យដោយច្បាប់ឬក្រោមកិច្ចសន្យារាប់បញ្ចូលទាំងការផ្តល់សម្បទានដើម្បីស្រាវជ្រាវដាំដុះ ធ្វើនិស្សារណកម្ម ឬធ្វើអាជីវកម្ម ធនធានធម្មជាតិ និង

(v) ការទាមទារសំណងជាប្រាក់ ឬគ្រប់ការអនុវត្តដែលមានតំលៃហិរញ្ញវត្ថុ ។

[២] សម្បទានពាណិជ្ជកម្ម រួមមានសិទ្ធិក្នុងកិច្ចសន្យា ដូចជាសិទ្ធិទាំងឡាយក្រោមកិច្ចសន្យាទទួលគំរោងរួចស្រេចសំរាប់ចាប់ផ្តើមប្រតិបត្តិការសាងសង់ គ្រប់គ្រង ផលិតកម្ម ឬបែកចែកចំណូល សម្បទាន ឬកិច្ចសន្យាស្រដៀងគ្នាផ្សេងទៀត និងអាចរាប់បញ្ចូលទាំងមូលនិធិវិនិយោគសំរាប់គំរោង ដូចជា គំរោងសាងសង់-ដំណើរការ និងផ្ទេរ (BOT) និង *គំរោងសាងសង់-ដំណើរការ* និងកាន់កាប់ (BOO) ។

ដោយឡែក **លក្ខខណ្ឌនៃការវិនិយោគ** មិនរាប់បញ្ចូលនូវការទាមទារសំណងជាប្រាក់ដែល កើតឡើងចំពោះ :

(i) កិច្ចសន្យាពាណិជ្ជកម្មស្តីពីការលក់ទំនិញ ឬសេវាកម្មដោយរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងដែនដីនៃភាគីមួយចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលក្នុងដែនដីនៃភាគីណាមួយផ្សេងទៀតឡើយ ។

(ii) ការពង្រីកឥណទាន ដោយមានការពាក់ព័ន្ធជាមួយប្រតិបត្តិការពាណិជ្ជកម្ម ដូចជាពាណិជ្ជកម្មហិរញ្ញវត្ថុ។

សំរាប់គោលបំណងនៃការកំណត់និយមន័យនៃវាក្យស័ព្ទ "ការវិនិយោគ" ក្នុងមាត្រានេះ ធនធានវិនិយោគត្រូវចាត់ទុកថា ជាការវិនិយោគ និងទំរង់ណាមួយផ្សេងទៀតនៃការវិនិយោគ ឬការវិនិយោគបន្តលើទ្រព្យធនដែលមិនប៉ះពាល់ដល់ប្រភេទនៃការវិនិយោគឡើយ ។

(ង) **អ្នកវិនិយោគរបស់ភាគីមួយ** មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គលរបស់ភាគីមួយ ដែលមានបំណងវិនិយោគទុន[៣] កំពុងវិនិយោគទុន ឬបានវិនិយោគទុននៅក្នុងដែនដីនៃភាគីណាមួយផ្សេងទៀត ។

(ច) **នីតិបុគ្គលរបស់ភាគីមួយ** មានន័យថា នីតិបុគ្គលណាមួយដែលបានបង្កើតឡើងត្រឹមត្រូវតាមលក្ខណៈច្បាប់ ឬបានរៀបចំឡើងតាមបែបផ្សេងទៀតត្រឹមត្រូវតាមច្បាប់ជាធរមានមិនថា ដើម្បីស្វែងរកផលកំរៃ ឬក្រៅពីនេះ និងមិនថាជា កម្មសិទ្ធិរបស់ឯកជន ឬរបស់រដ្ឋ ដែលរាប់បញ្ចូលទាំងសាជីវកម្ម ឯកាធិកម្ម សហកម្មសិទ្ធិ ឯកកម្មសិទ្ធិ សម្ព័ន្ធអាជីវកម្ម ឬសមាគមផ្សេងទៀត និងសាខា[៤]របស់វាដែលមានលក្ខណៈស្រដៀងគ្នា ។

(ឆ) **កូរ៉េ** មានន័យថា សាធារណរដ្ឋ កូរ៉េ ។

(ជ) **វិធានការ** មានន័យថា វិធានការណាមួយរបស់ភាគីមួយ ទោះជាស្ថិតក្នុងទំរង់នៃច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសំរេច និងសកម្មភាពរដ្ឋបាលឬក្នុងទំរង់ណាមួយផ្សេងទៀតដែលប៉ះពាល់ដល់អ្នកវិនិយោគ និង/ឬ ការវិនិយោគ និងរាប់បញ្ចូលទាំងវិធានការទាំងឡាយដែលបានប្រកាន់យកដោយ :

(i) រដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន និង

---

[៣] ដើម្បីឱ្យកាន់តែច្បាស់លាស់ ភាគីព្រមព្រៀងថា អ្នកវិនិយោគដែល "កំពុងស្វែងរក" ដាក់ទុនវិនិយោគ សំដៅលើអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត ដែលបានអនុវត្តនូវជំហានយ៉ាងសកម្មក្នុងការចាប់ផ្តើមធ្វើការជូនដំណឹង ឬដំណើរការសុំការអនុញ្ញាតតាម ករណីសមស្រប ដើម្បីសុំធ្វើការវិនិយោគ។

[៤] ដើម្បីឱ្យកាន់តែច្បាស់លាស់ សាខារបស់នីតិបុគ្គលដែលមិនមែនជាភាគីមិនត្រូវបានចាត់ទុកថា ជានីតិបុគ្គលនៃភាគីនោះទេ។

(ii) ស្ថាប័នមិនមែនរដ្ឋាភិបាលស្ថិតក្នុងក្របខ័ណ្ឌនៃការអនុវត្តសិទ្ធិអំណាច ដែលទទួលបានប្រតិភូកម្មពីរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋាន ។

(ន) **រូបវ័ន្តបុគ្គលរបស់ភាគី**[៥] មានន័យថា រូបវ័ន្តបុគ្គលដែលមានសញ្ជាតិ ឬការទទួលបានសញ្ជាតិ ឬសិទ្ធិនៃការស្នាក់នៅជាអចិន្ត្រៃយ៍នៅក្នុងទឹកដីនៃភាគីនោះ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ភាគីនោះ ។

(ប) **ភាគីក្រៅវិវាទ** មានន័យថា ភាគីនៃអ្នកវិនិយោគដែលកំពុងមានវិវាទ ។

(ផ) **ភាគីទាំងអស់** មានន័យថា បណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ និងកូរ៉េ ជារួម ។

(ព) **ភាគី** មានន័យថាប្រទេសជាសមាជិកអាស៊ានមួយ ឬកូរ៉េ ។

(ភ) **ផលពីការវិនិយោគ** មានន័យថាចំណូលប្រមូលបាន ឬកើតចេញពីការវិនិយោគ ជាពិសេសដោយមិនប្រមូលផ្តុំតែលើ ប្រាក់ចំណេញណាមួយ ការប្រាក់ ចំណូលមូលធន ភាគលាភ កំរៃសួយសារ ឬផល កំរៃផ្សេងៗទៀតនោះឡើយ ។

(ម) WTO មានន័យថាអង្គការពាណិជ្ជកម្មពិភពលោក និង

(យ) **កិច្ចព្រមព្រៀង WTO** មានន័យថា កិច្ចព្រមព្រៀងក្រុងម៉ារ៉ាកេស (Marrakesh) ស្តីពីការបង្កើតអង្គការ ពាណិជ្ជកម្មពិភពលោក ធ្វើឡើងនៅទីក្រុងម៉ារ៉ាកេស នាថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៩៤ រួមទាំង កិច្ចព្រមព្រៀងផ្សេងៗទៀតដែលបានចរចាពេលនោះ ។

## មាត្រា ២
## វិសាលភាពនៃការអនុវត្ត

១. កិច្ចព្រមព្រៀងនេះត្រូវអនុវត្តចំពោះវិធានការទាំងឡាយដែលបានអនុម័ត ឬកំណត់ឡើងដោយភាគីមួយពាក់ព័ន្ធនឹង :

(ក) អ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត នឹង

(ខ) ដែនវិនិយោគ

---

[៥] ក្នុងករណីភាគីដែលមិនផ្តល់សិទ្ធិស្នាក់នៅអចិន្ត្រៃយ៍ជូនជនបរទេស ឬផ្តល់ជូននិវាសនជនអចិន្ត្រៃយ៍របស់ខ្លួន នូវផលប្រយោជន៍ដូចគ្នាដែលផ្តល់ជូនជនជាតិខ្លួន ឬពលរដ្ឋដែលបានទទួលសញ្ជាតិខ្លួននោះ ខ្លួនពុំមានកាតព្វកិច្ចផ្លូវច្បាប់ណាមួយដែលតម្រូវឱ្យផ្តល់នូវអត្ថប្រយោជន៍ក្រោមកិច្ចព្រមព្រៀងនេះជូននិវាសនជនអចិន្ត្រៃយ៍របស់ភាគីណាមួយផ្សេងទៀត ឬទាមទារនូវអត្ថប្រយោជន៍ខាងលើសំរាប់និវាសនជនអចិន្ត្រៃយ៍របស់ខ្លួន ប្រសិនបើមានអនុវត្តពីភាគីណាមួយផ្សេងទៀតឡើយ ។

២. កិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះ :

(ក) លទ្ធកម្មសាធារណៈ

(ខ) ការឧបត្ថម្ភធន ឬការផ្តល់ជំនួយដោយភាគីមួយ និង

(គ) គ្រប់វិធានការពន្ធដារទាំងឡាយ លើកលែងករណីដូចមានចែងក្រោម មាត្រា១០ (ការផ្ទេរ) និង មាត្រា ១២ (ការដកហូត និងសំណង) ។

(ឃ) បណ្តឹងទាមទារដែលបានកើតឡើង ឬបណ្តឹងទាមទារដែលបានលើកឡើង មុនពេលកិច្ចព្រមព្រៀង នេះ ចូលជាធរមាន ។

(ង) ការផ្តត់ផ្គង់សេវាកម្ម ដែលស្ថិតក្នុងការអនុវត្តរបស់អាជ្ញាធររដ្ឋាភិបាលដូចជា ការអនុវត្តច្បាប់ សេវាកម្មកែតម្រូវ ចំណូលផ្នែកសន្តិសុខ ឬពីការធានារ៉ាប់រង សន្តិសុខសង្គម ឬការធានារ៉ាប់រង សង្គម សុខុមាលភាពសង្គម ការអប់រំបណ្តុះបណ្តាលសាធារណៈសុខភាព និងការថែទាំកុមារដែល ត្រូវបានផ្តត់ផ្គង់ ដោយមិនផ្អែកទាំងលើមូលដ្ឋានពាណិជ្ជកម្ម ទាំងលើមូលដ្ឋានប្រកួតប្រជែងជាមួយ អ្នកផ្តត់ផ្គង់សេវាមួយ ឬច្រើននោះឡើយ ។

(ច) វិធានការដែលបានអនុម័ត ឬកំណត់ឡើងដោយភាគីមួយ ក្នុងពេលដែលវិធានការទាំងនោះ ត្រូវបាន គ្រប់ដណ្តប់ដោយកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មផ្នែកសេវាកម្មស្ថិតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

៣. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ២ (ច) នៃមាត្រានេះក៏ដោយ មាត្រា ៥ (ប្រព្រឹត្តិកម្មទូទៅផ្នែកវិនិយោគ) មាត្រា ១០ (ការផ្ទេរ) មាត្រា ១២ (ការដកហូត និងសំណង) មាត្រា ១៣ (សំណងសំរាប់ការខាតបង់) មាត្រា ១៤ (ឧបាទេសកម្ម) និងមាត្រា ១៨ (ដំណោះស្រាយវិវាទវិនិយោគរវាងភាគីមួយ និងអ្នកវិនិយោគនៃភាគីណាមួយ ផ្សេងទៀត) នៃកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្ត mutatis mutandis ចំពោះវិធានការណាមួយដែលប៉ះពាល់ ដល់ការផ្តត់ផ្គង់សេវា ដោយអ្នកផ្តត់ផ្គង់សេវានៃភាគីមួយតាមរយៈវត្តមានពាណិជ្ជកម្ម[៦] នៅក្នុងដែនដីនៃភាគីណាមួយ ទៀត ដោយអនុលោមតាមបញ្ញត្តិកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មផ្នែកសេវាកម្មស្ថិតក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ សំរាប់តែ**វិធានការទាំងនោះពាក់ព័ន្ធ**ជាមួយ**ដែនវិនិយោគប៉ុណ្ណោះ** ។

## មាត្រា ៣

## ប្រព្រឹត្តិកម្មជាតិ[៧]

[៦] វត្តមានពាណិជ្ជកម្មត្រូវមានអត្ថន័យដូចគ្នានឹងអត្ថន័យនៅក្នុងកិច្ចព្រមព្រៀងស្តីពី ពាណិជ្ជកម្មសេវាកម្មក្រោមកិច្ចព្រមព្រៀង ក្របខ័ណ្ឌ។

[៧] ការអនុវត្តមាត្រានេះ ត្រូវអនុលោមទៅតាមមាត្រា ២៧ (កម្មវិធីការងារ) ។

ភាគីនីមួយៗត្រូវយល់ព្រមផ្តល់ជូនអ្នកវិនិយោគ និងដល់ដែនវិនិយោគនៃអ្នកវិនិយោគទាំងអស់នៃភាគីណាមួយផ្សេងទៀត ក្នុងកាលៈទេសៈដូចគ្នានូវប្រព្រឹត្តិកម្មមិនតិចជាងអ្វីដែលខ្លួនបានយល់ព្រមតាមរយៈវិធានការរបស់ខ្លួនផ្តល់ឱ្យអ្នកវិនិយោគ និងការវិនិយោគរបស់គេពាក់ព័ន្ធនឹងការអនុញ្ញាត ការបង្កើត ការទិញយក ការពង្រីក កិច្ចដំណើរការការគ្រប់គ្រង ការដឹកនាំ និងប្រតិបត្តិការ និងការលក់ ឬទំរង់ពាក់ព័ន្ធផ្សេងៗទៀតនៃការវិនិយោគក្នុងដែនដីវិនិយោគរបស់ខ្លួន។

## មាត្រា ៤
## ប្រព្រឹត្តិកម្មជាតិមានភាពអនុគ្រោះបំផុត[៨]

១. ភាគីនីមួយៗត្រូវផ្តល់ឱ្យចំពោះអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត នូវប្រព្រឹត្តិកម្មមិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យក្នុងកាលៈទេសៈដូចគ្នា ចំពោះអ្នកវិនិយោគនៃភាគី ឬមិនមែនភាគីណាមួយផ្សេងទៀត ពាក់ព័ន្ធនឹងការអនុញ្ញាត ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង កិច្ចដំណើរការ ការដឹកនាំ ប្រតិបត្តិការ និងការលក់ ឬទំរង់ពាក់ព័ន្ធផ្សេងៗទៀតនៃការវិនិយោគក្នុងដែនដីរបស់ខ្លួន ។

២. ភាគីនីមួយៗត្រូវផ្តល់ឱ្យដែនវិនិយោគនៃភាគីណាមួយផ្សេងទៀតនូវប្រព្រឹត្តិកម្ម មិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យក្នុងកាលៈទេសៈដូចគ្នាចំពោះការវិនិយោគ នៅក្នុងដែនដីរបស់ខ្លួននៃអ្នកវិនិយោគនៃភាគី ឬមិនមែនភាគីណាមួយផ្សេងទៀត ពាក់ព័ន្ធនឹងការអនុញ្ញាត ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង កិច្ចដំណើរការ ការដឹកនាំ ប្រតិបត្តិការ និងការលក់ ឬទំរង់ពាក់ព័ន្ធផ្សេងៗទៀតនៃការវិនិយោគ ។

៣. ប្រព្រឹត្តិកម្មដូចបានកំណត់ក្នុងកថាខ័ណ្ឌ ១ និង ២ មិនបានរួមបញ្ចូល :

(ក) រាល់ការយល់ព្រមផ្តល់ឱ្យ ប្រព្រឹត្តិកម្មអនុគ្រោះចំពោះអ្នកវិនិយោគនិង/ឬការវិនិយោគរបស់គេ ក្រោមកិច្ចព្រមព្រៀងទ្វេភាគីតំបន់ដែលមានស្រាប់ និង/ឬ កិច្ចព្រមព្រៀងអន្តរជាតិ ឬរាល់ទំរង់សេដ្ឋកិច្ចណាមួយ ឬសហប្រតិបត្តិការតំបន់ ជាមួយមិនមែនភាគីណាមួយ និង

(ខ) ប្រព្រឹត្តិកម្មអនុគ្រោះមានស្រាប់ ឬនៅពេលអនាគតណាមួយ ដែលផ្តល់ឱ្យចំពោះអ្នកវិនិយោគ និង/ឬការវិនិយោគរបស់គេ ក្នុងកិច្ចព្រមព្រៀង ឬការសំរុះសំរួលណាមួយរវាង ឬក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ។

៤. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ និង២ ក៏ដោយ ប្រសិនបើភាគីមួយផ្តល់នូវប្រព្រឹត្តិកម្មអនុគ្រោះបំផុតដល់អ្នកវិនិយោគនៃភាគី ឬមិនមែនភាគីណាមួយផ្សេងទៀត ឬការវិនិយោគរបស់គេ ដោយអាស្រ័យទៅលើកិច្ចព្រមព្រៀង ឬការសំរុះសំរួលណាមួយនាពេលអនាគតដែលភាគីជាភាគីចូលរួម ភាគីនោះនឹងមិនត្រូវមានកាតព្វកិច្ចក្នុងការផ្តល់

[៨] ការអនុវត្តមាត្រានេះ ត្រូវអនុលោមទៅតាមមាត្រា ២៧ (កម្មវិធីការងារ) ។

ប្រព្រឹត្តិកម្ម បែបនេះទៅអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត ឬការវិនិយោគរបស់គេឡើយ ។ ប៉ុន្តែ នៅពេលមានការស្នើសុំ ពីភាគីណាមួយផ្សេងទៀត ភាគីនឹងត្រូវផ្តល់ឱកាសគ្រប់គ្រាន់ ដើម្បីចរចាពីអត្ថប្រយោជន៍ត្រូវផ្តល់ជូន ។

## មាត្រា ៥
## ប្រព្រឹត្តិកម្មទូទៅនៃការវិនិយោគ

(១) ភាគីនីមួយៗ ត្រូវយល់ព្រមផ្តល់ដល់ដែនវិនិយោគនៃអ្នកវិនិយោគរបស់ភាគីណាមួយផ្សេងទៀតនូវ ប្រព្រឹត្តិកម្មប្រកបដោយភាពត្រឹមត្រូវ និងសមធម៌ ព្រមទាំង ការការពារ និងសុវត្ថិភាពពេញលេញផងដែរ ។

(២) ដើម្បីឱ្យកាន់តែប្រាកដ[៥]:

(ក) ប្រព្រឹត្តិកម្មត្រឹមត្រូវ និងសមធម៌ ទាមទារឱ្យភាគីនីមួយៗមិនត្រូវបដិសេធនូវយុត្តិធម៌ក្នុងរាល់ទំរង់ការតាមផ្លូវច្បាប់ ឬតាមផ្លូវរដ្ឋបាលណាមួយឡើយ ។

(ខ) ការការពារ និងសុវត្ថិភាពពេញលេញ ទាមទារឱ្យភាគីនីមួយៗចាត់វិធានការចាំបាច់និង សមស្រប ដើម្បីធានានូវការការពារ និងសុវត្ថិភាពនៃដែនវិនិយោគ និង

(គ) ទស្សនាទាននៃ "ប្រព្រឹត្តិកម្មត្រឹមត្រូវ និងសមធម៌" និង "ការការពារ និងសុវត្ថិភាពពេញលេញ" មិនទាមទារនូវប្រព្រឹត្តិកម្មបន្ថែម ឬហួសពីអ្វីដែលមានជាទំលាប់ក្រោមច្បាប់អន្តរជាតិ និងមិនបង្កើតនូវសិទ្ធិសំខាន់ៗបន្ថែមទៀតឡើយ ។

(៣) សេចក្តីសំរេចចិត្តណាមួយដែលមានចរិតជាការប្រព្រឹត្តិល្មើស ចំពោះបញ្ញត្តិដទៃទៀតនៃកិច្ចព្រមព្រៀងនេះ ឬកិច្ចព្រមព្រៀងអន្តរជាតិដោយឡែកណាមួយនោះ ពុំមានន័យថា ជាការប្រព្រឹត្តិល្មើសចំពោះមាត្រានេះឡើយ ។

[៥] សំរាប់ករណីសាធារណរដ្ឋឥណ្ឌូនេស៊ី កថាខ័ណ្ឌ២.គ. មិនត្រូវបានអនុវត្តនោះទេ ។

## មាត្រា ៦
## ការតម្រូវឱ្យបំពេញភាតព្វកិច្ច[១០]

១. បញ្ញត្តិនៃកិច្ចព្រមព្រៀងរបស់ WTO ស្តីពីវិធានការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម (TRIMs) ដែលមិនបានចែងជាក់លាក់ ឬកែប្រែដោយកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្ត Mutatis Mutandis នៃកិច្ចព្រមព្រៀងនេះ លើកលែងតែ បរិបទតម្រូវផ្សេងពីនេះ ។

## មាត្រា ៧
## គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល[១១]

១. ភាគីមួយមិនតម្រូវឱ្យនីតិបុគ្គលនៃភាគីនោះដែលជាដែនវិនិយោគ ធ្វើការតែងតាំងក្នុងតំណែង គណៈគ្រប់គ្រងជាន់ខ្ពស់ នូវរូបវន្តបុគ្គលនៃសញ្ជាតិណាមួយនោះទេ ។

២. ភាគីមួយអាចតម្រូវឱ្យភាគច្រើននៃក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការណាមួយ របស់នីតិបុគ្គលនៃភាគីនោះ ដែលជាដែនវិនិយោគ ជាសញ្ជាតិពិសេសមួយ ឬជានិវាសនជននៅក្នុងដែនដីនៃភាគី ក្នុងលក្ខណៈដែលតម្រូវការនោះមិនប៉ះពាល់ជាសំខាន់ដល់សមត្ថភាពនៃអ្នកវិនិយោគ ក្នុងការអនុវត្តការគ្រប់គ្រងលើការវិនិយោគរបស់គេទេនោះ ។

## មាត្រា ៨
## តម្លាភាព

១. ភាគីនីមួយៗត្រូវធ្វើការចុះផ្សាយជាបន្ទាន់ ឬពុំនោះទេ ធ្វើការប្រកាសជាសាធារណៈស្តីអំពីច្បាប់ បទប្បញ្ញត្តិ វិធានរដ្ឋបាល និងសេចក្តីសំរេចរបស់តុលាការ ស្តីពីការអនុវត្តទីជាទូទៅ ក៏ដូចជា កិច្ចព្រមព្រៀងអន្តរជាតិដែលទាក់ទិន ឬប៉ះពាល់ដល់បញ្ហាណាមួយដែលគ្របដណ្តប់ដោយកិច្ចព្រមព្រៀងនេះ ។

---

[១០] ការអនុវត្តមាត្រានេះ ត្រូវអនុលោមទៅតាមមាត្រា ២៧ (កម្មវិធីការងារ) ។

[១១] ការអនុវត្តមាត្រានេះ ត្រូវអនុលោមទៅតាមមាត្រា ២៧ (កម្មវិធីការងារ) ។

២. ភាគីនីមួយៗត្រូវធ្វើការប្រកាសជាសាធារណៈភ្លាមៗអំពីច្បាប់ថ្មី ឬរាល់ការកែប្រែនានានៅក្នុងច្បាប់ បទប្បញ្ញត្តិមានស្រាប់ បទប្បញ្ញត្តិ ឬគោលការណ៍ផ្នែករដ្ឋបាល ដែលមានការប៉ះពាល់ខ្លាំងដល់ការវិនិយោគ ឬការសន្យារបស់ភាគីមួយក្រោមកិច្ចព្រមព្រៀងនេះ ។

៣. បញ្ញត្តិនៃកថាខ័ណ្ឌទី ១ និង ២ មិនត្រូវបានបកស្រាយ ដើម្បីតម្រូវឱ្យភាគីមួយធ្វើការផ្សព្វផ្សាយនូវព័ត៌មានសំងាត់ឡើយ ដែលតាមរយៈការផ្សព្វផ្សាយនេះ វានឹងបង្អាក់ដល់ការអនុវត្តន៍ច្បាប់ ឬក្រៅពីនេះ វាជាករណីផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬវាប៉ះពាល់ដល់ឯកជនភាព ឬផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ថែមទៀត ។

៤. ភាគីនីមួយៗត្រូវបង្កើត ឬរៀបចំឱ្យមានមជ្ឈមណ្ឌលព័ត៌មានមួយ សំរាប់ផ្តល់ឱ្យបានទាន់ពេលវេលានូវព័ត៌មានទាំងឡាយទាក់ទិនទៅនឹងវិធានការដែលចាំបាច់ត្រូវចុះផ្សាយ ឬ ផ្តល់ជូនក្រោម កថាខ័ណ្ឌ ១ និង ២ តាមការស្នើសុំរបស់រូបវន្តបុគ្គល នីតិបុគ្គល ឬភាគីណាមួយផ្សេងទៀត ។

៥. ភាគីនីមួយៗត្រូវជូនដំណឹងដល់ភាគីផ្សេងទៀតទាំងអស់ តាមរយៈគណៈកម្មាធិការប្រតិបត្តិ យ៉ាងតិចបំផុតមួយដងក្នុងមួយឆ្នាំអំពីកិច្ចព្រមព្រៀង ឬការសំរុះសំរួលនានាទាក់ទិនទៅនឹងការវិនិយោគនាពេលអនាគត ដែលផ្តល់នូវប្រព្រឹត្តិកម្មអនុគ្រោះណាមួយ និងដែលខ្លួនជាភាគីចុះហត្ថលេខា។

៦. រាល់លិខិតជូនដំណឹង និងលិខិតទំនាក់ទំនងទាំងអស់ក្រោមកថាខ័ណ្ឌទី ៤ និង ៥ ត្រូវធ្វើឡើងជាភាសាអង់គ្លេស ។

## មាត្រា ៩
## ការបំរុងទុក[១២]

១. មាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត) មាត្រា ៧ (គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល) និងសំរាប់ករណីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មាត្រា ៦ (ការតម្រូវឱ្យបំពេញកាតព្វកិច្ច) មិនត្រូវអនុវត្តចំពោះ :

(ក) រាល់វិធានការមិនស្របគ្នាមានស្រាប់ ដែលកំណត់ដោយភាគីមួយនៅ :

(១) រដ្ឋាភិបាលថ្នាក់កណ្តាល ដូចមានចែងដោយភាគី នៅក្នុងតារាងស្តីពីការបំរុងទុករបស់ខ្លួននៅក្នុងបញ្ជីទី ១

(២) រដ្ឋាភិបាលថ្នាក់តំបន់ ដូចមានចែងដោយភាគី នៅក្នុងតារាងស្តីពីការបំរុងទុករបស់ខ្លួននៅក្នុងបញ្ជីទី ១ ឬ

(៣) រដ្ឋាភិបាលថ្នាក់មូលដ្ឋាន ។

---
[១២] ការអនុវត្តមាត្រានេះត្រូវអនុលោមទៅតាមមាត្រា ២៧ (កម្មវិធីការងារ) ។

(ខ) ការបន្ត ឬការរៀបចំជាថ្មីឡើងវិញជាបន្ទាន់នូវវិធានការមិនស្របគ្នា យោងតាមអនុកឋាខ័ណ្ឌ (ក) ឬ

(គ) វិសោធនកម្មនៃវិធានការមិនស្របគ្នាណាមួយ ដែលមានចែងនៅក្នុងអនុកឋាខ័ណ្ឌ (ក) ក្នុងពេលដែលវិសោធនកម្មនោះមិនបន្ថយនូវភាពស្របគ្នានៃវិធានការ ដូចដែលមាននៅកាលបរិច្ឆេទនៃការចូលជាធរមាននៃតារាងស្តីពីការបំរុងទុករបស់ភាគី នៅក្នុងបញ្ជីទី ១ ជាមួយនឹងមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត) មាត្រា ៧ (គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល) និងសំរាប់ករណី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មាត្រា ៦ (ការតម្រូវឱ្យបំពេញកាតព្វកិច្ច)។

២. មាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត) មាត្រា ៧ (គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល) និងសំរាប់ករណីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មាត្រា ៦ (ការតម្រូវឱ្យអនុវត្តកាតព្វកិច្ច) មិនត្រូវអនុវត្តលើការបំរុងទុកណាមួយសំរាប់វិធានការដែលភាគីមួយប្រកាន់យក ឬរក្សាទុកទាក់ទងទៅនឹងវិស័យ អនុវិស័យ ឬសកម្មភាពនានា ដូចមានចែងនៅក្នុងបញ្ជីទី ២ ឡើយ។

៣. ក្រៅពីអនុលោមទៅតាមនីតិវិធីនានាសំរាប់ការកែសំរួលតារាងស្តីពីការបំរុងទុក ក្រោមវិធានការដែលអនុម័តក្រោយកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងគ្របដណ្តប់ដោយបញ្ជីទី ២ ភាគីមួយមិនអាចទាមទារឱ្យអ្នកវិនិយោគនៃភាគីផ្សេងលក់ ឬក្រៅពីនេះ បោះបង់ចោលការវិនិយោគដែលមាននៅពេលដែលវិធានការនោះចូលជាធរមាន ដោយហេតុផលនៃសញ្ជាតិរបស់ភាគីនោះឡើយ។

៤. នីតិវិធីសំរាប់ការកែប្រែតារាងស្តីពីការបំរុងទុក យោងទៅលើកឋាខ័ណ្ឌទី ៣ ត្រូវអនុលោមទៅតាមមាត្រា ២៧ (កម្មវិធីការងារ)។

៥. ពុំមានចំណុចណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយដើម្បីដកហូតនូវសិទ្ធិ និងកាតព្វកិច្ចណាមួយក្រោមកិច្ចព្រមព្រៀងអន្តរជាតិ ទាក់ទិនទៅនឹងការការពារកម្មសិទ្ធិបញ្ញា ដែលភាគីក្នុងកិច្ចព្រមព្រៀងគឺជាភាគីនោះទេ ដោយរាប់បញ្ចូលទាំងកិច្ចព្រមព្រៀង WTO ស្តីពីបញ្ហាកម្មសិទ្ធិបញ្ញាទាក់ទងទៅនឹងពាណិជ្ជកម្ម (TRIPS) និងសន្ធិសញ្ញាផ្សេងទៀតដែលបានសំរេច ក្រោមការឧបត្ថម្ភរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

## មាត្រា ១០

## ការផ្ទេរ

១. ភាគីនីមួយៗត្រូវអនុញ្ញាតឱ្យមានការផ្ទេរ ទាក់ទិនទៅនឹងដែនវិនិយោគ ដោយសេរី និងភ្លាមៗនៅក្នុង ឬទៅក្រៅដែនដីរបស់ខ្លួន ជារូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី តាមអត្រាប្តូររូបិយប័ណ្ណនៅលើទីផ្សារ ដែលអនុវត្តនៅក្នុងដែនដីរបស់ខ្លួន នៅកាលបរិច្ឆេទផ្ទេរនោះ ។ ការផ្ទេរនោះ ត្រូវមាន ៖

(ក) ដើមទុនដំបូង និងចំនួនបន្ថែម ដើម្បីរក្សាទុក ឬបង្កើនការវិនិយោគ ។

(ខ) ផលចំណេញ ភាគលាភ ការប្រាក់ ផលចំណេញជាមូលធន ប្រាក់កំរៃសួយសារអាករ ថ្លៃអាជ្ញាប័ណ្ណ ថ្លៃជំនួយបច្ចេកទេស កំរៃនៃការគ្រប់គ្រង និងចំណូលចរន្តផ្សេងទៀត ដែលទទួលបានពីការវិនិយោគពាក់ព័ន្ធ ។

(គ) ផលចំណូលទទួលបានពីការលក់ ឬការរំលាយនូវផ្នែកណាមួយ ឬផ្នែកទាំងអស់នៃការវិនិយោគ ។

(ឃ) ប្រាក់ទូទាត់ដែលធ្វើឡើងក្រោមកិច្ចសន្យា ដោយរាប់បញ្ចូលទាំងការទូទាត់ក្រោមកិច្ចព្រមព្រៀងកម្ចីផងដែរ ។

(ង) ការទូទាត់ដែលធ្វើឡើង អនុលោមទៅតាមមាត្រា ១២ (ការដកហូត និងសំណង) និងមាត្រា ១៣ (ប្រាក់សំណងសំរាប់ការខាតបង់) និង

(ច) ប្រាក់ទូទាត់ដែលទទួលបានពីការដោះស្រាយវិវាទ ក្រោមកិច្ចព្រមព្រៀងនេះ ។

២. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌទី ១ ក៏ដោយ ភាគីអាចពន្យារ ឬបង្អាក់ការផ្ទេរបាន តាមរយៈការប្រើប្រាស់យ៉ាងសមធម៌ មិនរើសអើង និងក្នុងបំណងល្អនូវច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ទាក់ទិននឹង ៖

(ក) ភាពក្ស័យធន អសាធនភាព ឬការការពារសិទ្ធិឥណទាយក

(ខ) ការចេញ ការជួញដូរ ឬការទិញលក់មូលប័ត្រ ការទិញបំរុង ឬឧបករណ៍និស្សន្ទ

(គ) បទល្មើសព្រហ្មទណ្ឌ ឬឧក្រិដ្ឋផ្សេងៗ

(ឃ) សន្តិសុខសង្គម គំរោងការសន្សំចាំបាច់ ឬចូលនិវត្តន៍សាធារណៈ

(ង) ការធានាក្នុងការអនុវត្តន៍តាមសាលក្រម នៅក្នុងដំណើរការតាមផ្លូវតុលាការ ឬរដ្ឋបាល

(ច) សិទ្ធិទទួលបានប្រាក់បំណាច់របស់និយោជិត នៅពេលបញ្ចប់កិច្ចសន្យាការងារ

(ង) ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឬរក្សាកំណត់ត្រានៃការផ្ទេរ នៅពេលចាំបាច់ ដើម្បីជួយដល់ការអនុវត្តច្បាប់ ឬអាជ្ញាធរនិយ័តកម្មហិរញ្ញវត្ថុ និង

(ច) ការកំណត់ពន្ធដារ ។

៣. គ្មានចំណុចណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីដែលជាសមាជិករបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្រោមមាត្រានានានៃកិច្ចព្រមព្រៀងរបស់មូលនិធិ ដោយរាប់បញ្ចូលទាំងការប្រើប្រាស់សកម្មភាពដោះដូរដែលស្របទៅនឹងមាត្រាទាំងឡាយនៃកិច្ចព្រមព្រៀង ក្នុងលក្ខខណ្ឌថា ភាគីមួយមិនត្រូវដាក់បំរាមទៅលើ ប្រតិបត្តិការមូលធនណាមួយ ដែលមិនស្របទៅនឹងការប្តេជ្ញាជាក់លាក់របស់ខ្លួន ទាក់ទិនទៅប្រតិបត្តិការនោះឡើយ លើកលែងតែក្រោមមាត្រា ១១ (វិធានការការពារបណ្តោះអាសន្ន) ឬ តាមការស្នើសុំរបស់មូលនិធិប៉ុណ្ណោះ ។

## មាត្រា ១១
## វិធានការការពារបណ្តោះអាសន្ន

១. ភាគីអាចប្រកាន់យក ឬរក្សាទុកនូវវិធានការនានាដែលមិនស្របទៅនឹងកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) ទាក់ទិនទៅនឹងប្រតិបត្តិការមូលធនឆ្លងព្រំដែន ឬមាត្រា ១០ (ការផ្ទេរ) ក្នុងករណីមានសមតុល្យធ្ងន់ធ្ងរ និងការលំបាកផ្នែកហិរញ្ញវត្ថុខាងក្រៅ ឬក្រោមការគំរាមកំហែងនោះ ។

២. ភាគីអាចប្រកាន់យក ឬរក្សាទុកនូវវិធានការនានាដែលមិនស្របទៅនឹងកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រា ១០ (ការផ្ទេរ) ក្នុងកាលៈទេសមិនប្រក្រតីដែល ចលនាមូលធនបណ្តាលឱ្យ ឬគំរាមកំហែងនឹងបណ្តាលឱ្យកើតមាននូវវិបល្លាស ឬលំបាកធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច ឬហិរញ្ញវត្ថុ សំរាប់ប្រតិបត្តិការសាច់ប្រាក់ ឬគោលនយោបាយស្តីពីអត្រាប្តូរប្រាក់នៅក្នុង ភាគីដែលពាក់ព័ន្ធ[១៣] ។

៣. រាល់វិធានការដែលយោងទៅនឹងកឋាខណ្ឌ ១ និង ២ ត្រូវតែ :

(ក) អនុលោមទៅមាត្រានៃកិច្ចព្រមព្រៀងរបស់មូលនិធិអន្តរជាតិ IMF ដែលអាចនឹងមានការធ្វើវិសោធនកម្ម។

(ខ) បញ្ចៀសបាននូវការខូចខាតមិនចាំបាច់ចំពោះអត្ថប្រយោជន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ភាគីណាមួយផ្សេងទៀត ។

(គ) មិនហួសពីភាពចាំបាច់ក្នុងការដោះស្រាយជាមួយនឹងកាលៈទេសៈដូចបានពិពណ៌នានៅក្នុងកឋាខ័ណ្ឌទី ១ ឬ ទី ២ ។

---

[១៣] ដើម្បីទទួលបាននូវភាពប្រាកដប្រជាជាងនេះ រាល់វិធានការដែលចាត់ឡើងដើម្បីធានានូវស្ថេរភាពអត្រាប្តូរប្រាក់ រាប់បញ្ចូលទាំង ដើម្បីបង្កាលំហូរសាច់ ប្រាក់មិនប្រាកដប្រជា នឹងមិនត្រូវបានប្រកាន់យក ឬរក្សាទុកឡើយសំរាប់គោលបំណងការពារវិស័យមួយជាពិសេស ។

(ឃ) មានលក្ខណៈជាបណ្តោះអាសន្ន និងបញ្ចប់ជាបន្តបន្ទាប់ ខណៈពេលដែលស្ថានភាព ដូចមានចែងនៅក្នុងកថាខណ្ឌទី ១ រីកចំរើនទៅមុខ និង

(ង) ត្រូវបានអនុវត្ត ដែលភាគីណាមួយក្នុងចំណោមភាគីផ្សេងត្រូវទទួលបាននូវប្រព្រឹត្តិកម្ម មានការអនុគ្រោះមិនតិចជាងភាគី ឬមិនមែនភាគីផ្សេងទៀត។

៤. បន្ថែមពីលើចំណុច (ក) ដល់ចំណុច (ង) នៃកថាខ័ណ្ឌ ៣ ខាងលើ វិធានការដែលត្រូវបានប្រកាន់យក ឬរក្សាទុកដោយអនុលោមតាមខ្លឹមសារកថាខ័ណ្ឌ ២ នោះ ត្រូវតែ :

(ក) ត្រូវបានបញ្ចប់នៅក្នុងរយៈពេលមួយឆ្នាំ ឬនៅពេលដែលលក្ខខណ្ឌលែងតម្រូវឱ្យមានការអនុវត្ត ឬរក្សាទុកតទៅមុខទៀត។[១៤]

(ខ) ត្រូវបានអនុវត្តលើមូលដ្ឋានប្រព្រឹត្តិកម្មជាតិមួយ និង

(គ) បញ្ចៀសបាននូវការខូចខាតមិនចាំបាច់ចំពោះអ្នកវិនិយោគ និងដែនវិនិយោគរបស់ភាគីណាមួយផ្សេងទៀត ។

៥. រាល់ការកំណត់លក្ខខណ្ឌដែលត្រូវបានប្រកាន់យក ឬរក្សាទុកក្រោមកថាខ័ណ្ឌ ១ និង ២ ឬ ការផ្លាស់ប្តូរនានានៅក្នុងកថាខ័ណ្ឌទាំងនោះ នឹងត្រូវបានជូនដំណឹងដល់ភាគីផ្សេងៗទៀតជាបន្ទាន់ ។

## មាត្រា ១២
## ការដកហូត និងសំណង

១. ភាគីមួយមិនអាចធ្វើជាតូបនីយកម្ម ឬដកហូតការវិនិយោគរបស់អ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀតឡើយដោយផ្ទាល់ ឬតាមរយៈវិធានការណាមួយដែលប្រហាក់ប្រហែលទៅនឹងការដកហូត ឬការធ្វើជាតូបនីយកម្ម (តទៅហៅថា "ការដកហូត") លើកលែងតែ :

(ក) ក្នុងគោលបំណងបំរើផលប្រយោជន៍សាធារណៈ[១៥]

(ខ) អនុលោមទៅតាមដំណើរការយ៉ាងត្រឹមត្រូវរបស់ច្បាប់

(គ) ដោយពុំមានការរើសអើង និង

(ឃ) ផ្តល់នូវសំណងភ្លាមៗ យ៉ាងសមរម្យ និងមានប្រសិទ្ធភាព

---

[១៤] ដើម្បីទទួលបាននូវភាពប្រាកដប្រជាជាងនេះ វិធានការអាចនឹងត្រូវបានពន្យារលើសពីមួយឆ្នាំ ប្រសិនបើមានការ ធានាក្រោមលក្ខខណ្ឌ។

[១៥] ដើម្បីឱ្យច្បាស់ សំរាប់ករណីប្រទេសម៉ាឡេស៊ីគឺជាប្រទេសដែលធ្វើការដកហូត រាល់វិធានការអស្សាមិករណ៍ទាក់ទិនទៅនឹងដីត្រូវធ្វើឡើងក្នុងគោលបំណងដូចមានចែងនៅក្នុងច្បាប់ និងបទបញ្ញត្តិក្នុងស្រុក ទាក់ទិនទៅនឹងការទិញយកដី។

២. សំរាប់គោលបំណងនៃកថាខ័ណ្ឌ ១ (ឃ) ប្រាក់សំណងត្រូវ ៖

(ក) ស្មើនឹងតំលៃទីផ្សារយ៉ាងសមរម្យនៃការវិនិយោគដែលដកហូត នៅពេលដែលការដកហូតត្រូវបានប្រកាសជាសាធារណៈ ឬនៅពេលដកហូត ដោយយកមួយណាដែលអនុវត្តបាន។[១៦]

(ខ) មិនមានការប្រែប្រួលតំលៃ ដោយហេតុថា ការដកហូតដែលបំរុងនឹងអនុវត្ត ត្រូវបានដឹងឮជាមុនរួចហើយ ។

(គ) បានដោះស្រាយ និងទូទាត់ ដោយពុំមានការពន្យារពេលមិនសមហេតុផលឡើយ ។[១៧]

(ឃ) អនុវត្តប្រកបដោយប្រសិទ្ធភាព និងអាចផ្ទេរដោយសេរី រវាងដែនដីរបស់ភាគី ។

៣. សំណងដែលចែងនៅក្នុងកថាខ័ណ្ឌទី ១ (ឃ) ត្រូវរាប់បញ្ចូលទាំងការប្រាក់ផងដែរ ។ ប្រាក់សំណង រួមទាំងការប្រាក់ ត្រូវបានទូទាត់ជារូបិយប័ណ្ណរបស់ភាគីដកហូត ឬជារូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី ប្រសិនបើមានសំណើរបស់អ្នកវិនិយោគ ។

៤. ថ្វីបើមានចែងនៅក្នុងកថាខ័ណ្ឌទី ១ ២ និង ៣ ក៏ដោយ សំរាប់ករណីសាធារណរដ្ឋសិង្ហបូរី និងសាធារណរដ្ឋសង្គមនិយមវៀតណាម រាល់វិធានការនៃការដកហូតទាក់ទិនទៅនឹងដីត្រូវកំណត់នៅក្នុងច្បាប់ បទប្បញ្ញត្តិក្នុងស្រុកនីមួយៗ និងវិសោធនកម្មនានាដែលមាន និងត្រូវស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិខាងលើ សំរាប់គោលបំណងនឹងការ ទូទាត់ប្រាក់សំណង ។

៥. មាត្រានេះមិនអនុវត្តចំពោះការចេញដោយខានមិនបាននូវអាជ្ញាប័ណ្ណ ទាក់ទិនទៅនឹងកម្មសិទ្ធិបញ្ញា ក្រោមកិច្ចព្រមព្រៀង (TRIPS) នោះឡើយ ។

## មាត្រា ១៣

## សំណងសំរាប់ការខាតបង់

ភាគីមួយត្រូវយល់ព្រមចំពោះអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត ដែលដែនវិនិយោគរបស់ពួកគេរងនូវការខាតបង់ដោយសារសង្គ្រាម ឬជំលោះប្រដាប់អាវុធផ្សេងទៀត ស្ថានភាពអាសន្នរបស់ជាតិ ជំលោះស៊ីវិល ឬព្រឹត្តិការណ៍ស្រដៀងគ្នានេះផ្សេងទៀត នៅក្នុងដែនដីរបស់ខ្លួន នូវប្រព្រឹត្តិកម្មអនុគ្រោះមិនតិចជាងអ្វីដែលខ្លួនបានផ្តល់

---

[១៦] សំរាប់ករណីប្រទេសហ្វីលីពីន នៅពេល ឬភ្លាម១មុនធ្វើការប្រកាសដកហូតជាសាធារណៈ ត្រូវយោងទៅកាលបរិច្ឆេទដាក់បណ្តឹងសារទុក្ខស្តីពីការដកហូតនោះ ។

[១៧] ភាគីព្រមព្រៀងថា អាចនឹងមានដំណើរការក្តីតាមផ្លូវច្បាប់ ឬរដ្ឋបាលត្រូវធ្វើឡើង មុននឹងមានការទូទាត់ប្រាក់ ។

ជូនអ្នកវិនិយោគខ្លួន ឬអ្នកវិនិយោគរបស់មិនមែនភាគី សំរាប់កាលៈទេសៈដូចគ្នា ដោយយកមួយណាដែលអនុគ្រោះជាង ទាក់ទិនទៅនឹងបដិទាន ការផ្តល់សំណង សំណង ឬទំរង់នៃការដោះស្រាយផ្សេងៗទៀត ។

## មាត្រា ១៤

## ឧបាទេសកម្ម

១. ក្នុងករណីដែលភាគី ឬទីភ្នាក់ងារដែលទទួលបានសិទ្ធិពីភាគីបានផ្តល់កិច្ចសន្យាធានារ៉ាប់រង ឬទំរង់ណាមួយនៃការធានាផ្នែកហិរញ្ញវត្ថុសំរាប់ហានិភ័យមិនមែនពាណិជ្ជកម្ម ទាក់ទិនទៅនឹងដែនវិនិយោគរបស់អ្នកវិនិយោគម្នាក់នៃអ្នកវិនិយោគរបស់ខ្លួន ក្នុងដែនដីរបស់ភាគីផ្សេង ហើយនៅពេលដែលធ្វើការទូទាត់ក្រោមកិច្ចសន្យា ឬក្រោមការធានាផ្នែកហិរញ្ញវត្ថុនេះរបស់ភាគី ឬទីភ្នាក់ងាររបស់ភាគីដែលបានទទួលសិទ្ធិ ភាគីផ្សេងទៀតដែលជាម្ចាស់ទឹកដីសំរាប់វិនិយោគត្រូវទទួលស្គាល់សិទ្ធិរបស់ភាគី ឬទីភ្នាក់ងារដែលទទួលបានសិទ្ធិពីភាគី ដោយអនុលោមទៅតាមគោលការណ៍នៃឧបាទេសកម្មចំពោះសិទ្ធិរបស់អ្នកវិនិយោគ ។[១៨]

២. ក្នុងករណីដែលភាគី ឬទីភ្នាក់ងារដែលទទួលសិទ្ធិពីភាគីបានធ្វើការទូទាត់ប្រាក់ជូនអ្នកវិនិយោគរបស់ខ្លួន និងបានទទួលសិទ្ធិ ព្រមទាំងការអះអាងតវ៉ារបស់អ្នកវិនិយោគ អ្នកវិនិយោគនោះ មិនត្រូវធ្វើការទាមទារសិទ្ធិ និងតវ៉ាចំពោះភាគីផ្សេងទៀតឡើយ លើកលែងតែទទួលបាននូវការអនុញ្ញាតឱ្យអនុវត្តជំនួសភាគី ឬទីភ្នាក់ងារដែលទទួលបានសិទ្ធិពីភាគីដើម្បីធ្វើការទូទាត់នោះ ។[១៩]

## មាត្រា ១៥

## ទម្រង់ការពិសេស និងប្រព្រឹត្តិកម្មព័ត៌មាន

១. ពុំមានចំណុចណាមួយនៅក្នុងមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) ត្រូវបានបកស្រាយថា ជាការទប់ស្កាត់ភាគីមួយមិនឱ្យប្រកាន់យក ឬរក្សាទុកនូវវិធានការដែលមានបែបបទពិសេស ទាក់ទិននឹងការបង្កើតការវិនិយោគរបស់អ្នកវិនិយោគរបស់ភាគីណាមួយផ្សេងទៀត ដូចជាការតម្រូវឱ្យការវិនិយោគត្រូវបង្កើតឡើងស្របច្បាប់ ក្រោមច្បាប់ ឬ បទប្បញ្ញត្តិរបស់ភាគី និងត្រូវអនុវត្តតាមបែបបទនៃការចុះបញ្ជី ក្នុងលក្ខខណ្ឌថា បែបបទទាំងនេះមិនប៉ះពាល់អ្វីជាសំខាន់ដល់

---

[១៨] ដើម្បីឱ្យកាន់តែច្បាស់ សិទ្ធិដែលបានផ្ទេរ ឬបណ្តឹងមិនត្រូវមានទំហំធំជាងសិទ្ធិ ឬបណ្តឹងដើមរបស់អ្នកវិនិយោគ ឡើយ ។

[១៩] ដើម្បីឱ្យកាន់តែច្បាស់ មាត្រា ១០ (ការផ្ទេរ) មាត្រា ១២ (ការដកហូត និងសំណង) និងមាត្រា ១៣ (សំណងសំរាប់ការខាតបង់) ត្រូវអនុវត្តរួមបញ្ចូលទាំងផ្នែកវិសោធនកម្មផងដែរ ទាក់ទិនទៅនឹងការទូទាត់ដែលត្រូវធ្វើ ឡើងជូនភាគី ឬទីភ្នាក់ងារដែលមានចែងក្នុង*កថាខ័ណ្ឌទី ១* និង ២ ដោយអនុលោមទៅតាមការទទួលស្គាល់សិទ្ធិ និង បណ្តឹង និងការផ្ទេរទឹកប្រាក់ទូទាត់នោះ ។

សិទ្ធិដែលភាគីមួយផ្តល់ជូនអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត និងការវិនិយោគរបស់អ្នកវិនិយោគនៃភាគីណាមួយផ្សេងក្រោមកិច្ចព្រមព្រៀងនេះ ។

២. ថ្វីបើមានចែងក្នុងមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) ឬ មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិមានភាពអនុគ្រោះបំផុត) ក៏ដោយ ភាគីមួយអាចទាមទារឱ្យអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត ឬការវិនិយោគរបស់គេនៅក្នុងដែនដីរបស់ខ្លួន ក្នុងការផ្តល់នូវព័ត៌មានជាប្រចាំទាក់ទិនទៅនឹងការវិនិយោគទាំងនោះ ដើម្បីបំរើតែគោលបំណងព័ត៌មាន ឬស្ថិតិ ប៉ុណ្ណោះ ។ ភាគីត្រូវការពារព័ត៌មានសំងាត់ដែលទទួលបាន ដោយមិនត្រូវបញ្ចេញឱ្យគេដឹងឡើយ ក្នុងលក្ខខណ្ឌដែលថា ការផ្សព្វផ្សាយព័ត៌មានទាំងនោះ នឹងធ្វើឱ្យខូចខាតដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់នីតិបុគ្គលណាមួយ ជាសាធារណៈ ឬជាឯកជន ឬប៉ះពាល់ដល់ភាពប្រកួតប្រជែងរបស់អ្នកវិនិយោគ ឬការវិនិយោគ។ ពុំមានចំណុចណាមួយក្នុងកថាខ័ណ្ឌនេះ ត្រូវបានបកស្រាយថា ជាការទប់ស្កាត់ភាគីមួយមិនឱ្យទទួល ឬបញ្ចេញព័ត៌មានទាក់ទិនទៅនឹងការអនុវត្តច្បាប់របស់ខ្លួន ដោយសមធម៌ និងស្មោះត្រង់នោះឡើយ ។

## មាត្រា ១៦
## ប្រព្រឹត្តិកម្មពិសេស និងផ្សេងៗគ្នាសំរាប់ប្រទេសជាសមាជិកថ្មីនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

ដើម្បីបង្កើនអត្ថប្រយោជន៍សំរាប់ប្រទេសជាសមាជិកថ្មីនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ក្នុងការចូលរួមកិច្ចព្រមព្រៀងនេះ និងអនុលោមទៅតាមកម្មវត្ថុដែលមានចែងក្នុងបុព្វកថានៃកិច្ចព្រមព្រៀងនេះ និងនៅក្នុងកិច្ចព្រមព្រៀងក្របខ័ណ្ឌ ប្រព្រឹត្តិកម្មពិសេស និងផ្សេងៗគ្នាត្រូវអនុវត្តចំពោះប្រទេសទាំងនេះ ក្នុងកំរិតកំណត់មួយដែលអាចធ្វើបាន តាមរយៈ :

(ក) ការទទួលបាននូវព័ត៌មានស្តីពីគោលនយោបាយវិនិយោគរបស់ភាគីផ្សេង ព័ត៌មានអាជីវកម្ម សំណុំទិន្នន័យពាក់ព័ន្ធ និងចំណុចទាក់ទងសំរាប់ការជំរុញការវិនិយោគ ។

(ខ) ជំនួយបច្ចេកទេសដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេ ទាក់ទិនទៅនឹងគោលនយោបាយវិនិយោគ និងការជំរុញវិនិយោគ ដោយរាប់បញ្ចូលទាំងក្នុងផ្នែក ដូចជា ការអភិវឌ្ឍន៍ធនធានមនុស្សផងដែរ ។

(គ) ការប្តេជ្ញាដើម្បីផលប្រយោជន៍របស់ប្រទេសជាសមាជិកថ្មីនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង

(ឃ) ទទួលស្គាល់ថា ការប្តេជ្ញារបស់ប្រទេសជាសមាជិកថ្មីនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍នីមួយៗ អាចត្រូវបានអនុវត្ត ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍នៃប្រទេសរៀងៗខ្លួន ។

## មាត្រា ១៧
## ការបដិសេធផលប្រយោជន៍

១. ភាគីមួយអាចបដិសេធមិនផ្តល់នូវផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ជូនអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត ដែលជានីតិបុគ្គលនៃភាគីផ្សេងនោះ និងដល់ការវិនិយោគរបស់អ្នកវិនិយោគនោះ ប្រសិនបើនីតិបុគ្គលពុំមានសកម្មភាពអាជីវកម្មជាមូលដ្ឋាននៅក្នុងដែនដីរបស់ភាគី ក្រោមច្បាប់ដែលខ្លួនបានបង្កើត ឬរៀបចំ និងអ្នកវិនិយោគរបស់មិនមែនជាភាគី ឬរបស់ភាគីដែលធ្វើការបដិសេធន៍ គ្រប់គ្រងជាម្ចាស់ ឬត្រួតត្រានីតិបុគ្គល ។

២. ភាគីដែលបដិសេធន៍ត្រូវជូនដំណឹងតាមលទ្ធភាពដែលអាចអនុវត្តបាន ដល់ភាគីផ្សេងពាក់ព័ន្ធ មុននឹងធ្វើការបដិសេធផលប្រយោជន៍នោះ ។ ប្រសិនបើភាគីដែលបដិសេធន៍ផ្តល់នូវការជូនដំណឹងនេះ ខ្លួនត្រូវពិភាក្សាជាមួយនឹងភាគីផ្សេងដែលពាក់ព័ន្ធ តាមសំណើរបស់ភាគីផ្សេងនោះ ។

៣. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌទី ១ និងអនុលោមតាមការជូនដំណឹងជាមុន និងការពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធក៏ដោយ សំរាប់ករណីព្រះរាជាណាចក្រថៃ ព្រះរាជាណាចក្រថៃអាចបដិសេធមិនផ្តល់ផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ទាក់ទិនទៅនឹងការអនុញ្ញាត ការបង្កើត ការទិញយក និងការពង្រីកការវិនិយោគ ដល់អ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀតដែលជានីតិបុគ្គលរបស់ភាគីផ្សេងនោះ និងដល់ការវិនិយោគរបស់អ្នកវិនិយោគនោះ ក្នុងករណីដែលព្រះរាជាណាចក្រថៃរកឃើញថា នីតិបុគ្គលនោះត្រូវបានកាន់កាប់ ឬត្រួតត្រាដោយរូបវន្តបុគ្គល ឬ នីតិបុគ្គលនៃប្រទេសមិនមែនជាភាគី ។

៤. សំរាប់ករណីព្រះរាជាណាចក្រថៃ នីតិបុគ្គលត្រូវបាន :

(ក) កាន់កាប់ដោយអ្នកវិនិយោគនៃភាគីមួយ ប្រសិនបើជាង ៥០ ភាគរយនៃភាគហ៊ុនដែលមាននៅក្នុងនីតិបុគ្គល ជារបស់អ្នកវិនិយោគ និង

(ខ) ត្រូវបានត្រួតត្រាដោយអ្នកវិនិយោគនៃភាគីមួយ ប្រសិនបើអ្នកវិនិយោគនោះមានអំណាច ក្នុងការតែងតាំងភាគច្រើននៃអភិបាល ក្នុងក្រុមប្រឹក្សាភិបាល ឬក្រៅពីនេះ ក្នុងការដឹកនាំបញ្ជាសកម្មភាពរបស់នីតិបុគ្គលដោយស្របច្បាប់ ។

៥. បន្ទាប់ពីការជូនដំណឹង និងដោយពុំមានប៉ះពាល់ដល់កថាខ័ណ្ឌ ១ សំរាប់ករណី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋហ្វីលីពីនអាចបដិសេធមិនផ្តល់ផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ជូនដល់អ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត និងដល់ការវិនិយោគរបស់អ្នកវិនិយោគនោះ ក្នុងករណីដែលខ្លួនរកឃើញថា អ្នកវិនិយោគនោះបានធ្វើការវិនិយោគ

ដោយបំពានបញ្ញត្តិនៃច្បាប់សហធន Commonwealth Act លេខ ១០៨ (ច្បាប់ស្តីពីការដាក់ពិន័យចំពោះអំពើគេចវេសពីច្បាប់ស្តីពីការធ្វើជាតួបនីយកម្មនូវសិទ្ធិខ្លះ សិទ្ធិទទួលបានពីម្ចាស់ដើម ឬបុព្វសិទ្ធិ) ដូចបានធ្វើវិសោធនកម្មដោយក្រឹត្យលេខ ៧១៥ ឬក្រៅពីនេះ ហៅថា "The Anti-Dummy Law" ដូចដែលអាចធ្វើវិសោធនកម្ម ។

## មាត្រា ១៨
## ដំណោះស្រាយវិវាទវិនិយោគ
## រវាងភាគីមួយ និងអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត

១. មាត្រានេះត្រូវអនុវត្តចំពោះវិវាទវិនិយោគរវាងភាគីមួយ និងអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត ទាក់ទិនទៅនឹងការចោទប្រកាន់អំពីការប្រព្រឹត្តល្មើសមាត្រា ៣ (ប្រព្រឹត្តិកម្មជាតិ) មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិមានភាពអនុគ្រោះបំផុត) មាត្រា ៥ (ប្រព្រឹត្តិកម្មទូទៅនៃការវិនិយោគ) មាត្រា ៧ (គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល) មាត្រា ១០ (ការផ្ទេរ) មាត្រា ១២ (ការដកហូត និងសំណង) និង មាត្រា ១៣ (សំណងសំរាប់ការខាតបង់) នៃកិច្ចព្រមព្រៀងនេះ ដែលបណ្តាលឱ្យមានការខាតបង់ ឬខូចខាត ដោយមូលហេតុកើតចេញពីការប្រព្រឹត្តល្មើសនោះដល់ :

(ក) អ្នកវិនិយោគ ទាក់ទិនទៅនឹងដែនវិនិយោគរបស់គេ ឬ

(ខ) ដែនវិនិយោគដែលបានដំណើរការដោយអ្នកវិនិយោគ ទាក់ទិនទៅនឹងការគ្រប់គ្រង ការអនុវត្តនីប្រតិបត្តិការ ឬការលក់ ឬការចាត់ចែងផ្សេងៗទៀតនៃដែនវិនិយោគ ។

២. រូបវន្តបុគ្គលដែលមានសញ្ជាតិ ឬជាប្រជាពលរដ្ឋរបស់ភាគី មិនត្រូវធ្វើបណ្តឹងតវ៉ាចំពោះភាគីនោះ ក្រោមកិច្ចព្រមព្រៀងនេះឡើយ ។

៣. ការវិនិយោគមិនអាចធ្វើបណ្តឹងបាន ក្រោមកិច្ចព្រមព្រៀងនេះឡើយ ។

៤. ក្នុងករណីវិវាទវិនិយោគកើតឡើងក្រោមមាត្រានេះ ភាគីមានវិវាទត្រូវដោះស្រាយវិវាទតាមរយៈ ការពិភាក្សា និងចរចាគ្នា តាមលទ្ធភាពដែលអាចធ្វើទៅបាន តាមរយៈសំណើជាលាយលក្ខណ៍អក្សរ ដើម្បីសំរេចបាននូវការដោះស្រាយមួយជាលក្ខណៈមិត្តភាព ។

៥. វិវាទណាមួយដែលពុំអាចដោះស្រាយបានក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរ សុំឱ្យមានការពិភាក្សានោះ អាចត្រូវបញ្ជូនទៅតុលាការ ឬសាលាក្តីរដ្ឋបាលនៃភាគីមានវិវាទ ក្នុងលក្ខខណ្ឌថា តុលាការ ឬសាលាក្តីនោះមានយុត្តាធិការលើបណ្តឹង ឬចំពោះមជ្ឈត្តវិនិច្ឆ័យនោះ ។ ក្នុងករណីបែបនេះ អ្នកវិនិយោគអាចធ្វើការ ជ្រើសរើសក្នុងចំណោមជំរើសដូចខាងក្រោម :

(ក) អនុសញ្ញា ICSID និងវិធាន ICSID ស្តីពីនីតិវិធីនៃដំណើរការមជ្ឈត្តវិនិច្ឆ័យ ក្នុងលក្ខខណ្ឌថា ទាំងភាគីវិវាទ និងភាគីមិនមានវិវាទសុទ្ធតែជាភាគីនៃអនុសញ្ញា ICSID ។[២០]

(ខ) វិធានគ្រប់គ្រងយន្តការផ្តល់សេវាកម្មបន្ថែម ICSID ក្នុងលក្ខខណ្ឌថា ភាគីវិវាទ ឬភាគីមិនមានវិវាទ ជាភាគីមួយនៃអនុសញ្ញា ICSID ។

(គ) វិធានអាជ្ញាកណ្តាលនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ UNCITRAL ឬ

(ឃ) ស្ថាប័នមជ្ឈត្តវិនិច្ឆ័យផ្សេងៗទៀត ឬវិធានមជ្ឈត្តវិនិច្ឆ័យផ្សេងមួយទៀត ប្រសិនបើភាគីមានវិវាទ ព្រមព្រៀងគ្នា ។

៦. នៅពេលដែលអ្នកវិនិយោគបានបញ្ជូនវិវាទទៅតុលាការ ឬសាលាក្តីរដ្ឋបាលនៃភាគីមានវិវាទ ឬយន្តការមជ្ឈត្តវិនិច្ឆ័យណាមួយដូចមានចែងក្នុងកថាខ័ណ្ឌទី ៥ នោះ ជំរើសនេះត្រូវជាជំរើសចុងក្រោយ ។

៧. ការបញ្ជូនវិវាទទៅកាន់មជ្ឈត្តវិនិច្ឆ័យ ក្រោមកថាខ័ណ្ឌទី ៥ ត្រូវស្ថិតក្រោមលក្ខខណ្ឌដូចតទៅ :

(ក) ការបញ្ជូនវិវាទទៅមជ្ឈត្តវិនិច្ឆ័យណាមួយខាងលើនេះ ត្រូវធ្វើឡើងក្នុងរយៈពេលបីឆ្នាំ ក្រោយពេលដែលអ្នកវិនិយោគមានវិវាទបានដឹង ឬគួរដឹងយ៉ាងសមហេតុផល អំពីការប្រព្រឹត្តល្មើសកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ និងអំពីការខាតបង់ ឬការខូចខាតដែលកើតមានឡើងដោយអ្នកវិនិយោគមានវិវាទ ទាក់ទិនទៅនឹងដែនវិនិយោគរបស់គេ ឬដោយដែនវិនិយោគ និង

(ខ) អ្នកវិនិយោគមានវិវាទជូនដំណឹងជាលាយលក្ខណ៍អក្សរជូនភាគីមានវិវាទយ៉ាងតិចបំផុត ៩០ ថ្ងៃ មុនពេលដាក់បណ្តឹងទៅមជ្ឈត្តវិនិច្ឆ័យអំពីគោលបំណងរបស់ខ្លួន ក្នុងការបញ្ជូនវិវាទទៅកាន់មជ្ឈត្តវិនិច្ឆ័យនោះ និងដែល :

(១) រៀបចំវេទិកាមួយក្នុងចំណោមវេទិកាដែលមានចែងក្នុងកថាខ័ណ្ឌទី ៥ (ក) (ខ) (គ) ឬ (ឃ) ជាវេទិកាសំរាប់ដោះស្រាយវិវាទ និង

(២) សង្ខេបការប្រព្រឹត្តល្មើសដែលបានចោទប្រកាន់របស់ភាគីមានវិវាទ ក្រោមកិច្ចព្រមព្រៀងនេះ (ដោយរាប់បញ្ចូលទាំងមាត្រាដែលត្រូវបានចោទប្រកាន់ថាមានការប្រព្រឹត្តល្មើស) និងការ

[២០] ក្នុងករណីសាធារណរដ្ឋហ្វីលីពីន ការដាក់បណ្តឹងក្រោម *អនុសញ្ញា ICSID* និង *វិធានគ្រប់គ្រងយន្តការផ្តល់សេវាកម្មបន្ថែម ICSID ស្តីពីនីតិវិធីដំណើរការមជ្ឈត្តវិនិច្ឆ័យ* ត្រូវអនុលោមទៅតាមកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងភាគីវិវាទ ក្នុងករណីដែលវិវាទវិនិយោគកើតមានឡើង ។ ដើម្បីឱ្យកាន់តែច្បាស់ គ្មានចំណុចណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះត្រូវបានបកស្រាយថា ជាការលើកលែងមិនឱ្យមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងចំណុចសំគាល់នៅជើងទំព័រនេះឡើយ ។

ខាតបង់ ឬការខូចខាតចំពោះអ្នកវិនិយោគ ទាក់ទិនទៅនឹងដែនវិនិយោគរបស់គេ ឬចំពោះដែនវិនិយោគ ។[២១]

៨. ក្នុងករណីដែលវិវាទវិនិយោគមានជាប់ទាក់ទិនទៅនឹងវិធានការដែលអាចជាវិធានការពន្ធដារនោះ ភាគីវិវាទ និងភាគីមិនមានវិវាទ ដោយរាប់បញ្ចូលទាំងតំណាងនៃរដ្ឋបាលពន្ធដាររបស់ខ្លួន ត្រូវធ្វើពិគ្រោះយោបល់ដើម្បីកំណត់ថា តើវិធានការជាបញ្ហានោះ ជាវិធានការពន្ធដារឬមិនមែន ?

៩. ក្នុងករណីដែលអ្នកវិនិយោគមានវិវាទប្តឹងថា ភាគីមានវិវាទបានប្រព្រឹត្តល្មើសមាត្រា ១២ (ការដកហូត និងសំណង) ដោយប្រកាន់យក ឬអនុវត្តវិធានការពន្ធដារនោះ ភាគីមានវិវាទ និងភាគីមិនមានវិវាទ តាមសំណើរបស់ភាគីមានវិវាទ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយគ្នា ដើម្បីកំណត់ថា តើវិធានការពន្ធដារដែលជាបញ្ហានោះ មានតំលៃស្មើទៅនឹងការដកហូត ឬការធ្វើជាតូបនីយកម្មដែរឬទេ?

១០. រាល់សាលាក្តីដែលបានជ្រើសរើសក្រោមមាត្រានេះ ត្រូវស្របទៅតាមការសំរេចក្រោមការពិចារណាយ៉ាងល្អិតល្អន់របស់ភាគីវិវាទ និងភាគីមិនមានវិវាទ ក្រោមកឋាខ័ណ្ឌទី ៨ និង ៩ ។

១១. ប្រសិនបើភាគីមានវិវាទ និងភាគីមិនមានវិវាទមិនបានចាប់ផ្តើមធ្វើការពិគ្រោះយោបល់គ្នា ដូចមានចែងនៅក្នុងកឋាខ័ណ្ឌទី ៨ និង ៩ ឬធ្វើការសំរេចរួមគ្នា ក្នុងរយៈពេល ១៨០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានសំណើសុំការពិគ្រោះយោបល់ ដូចមានចែងក្នុងកឋាខ័ណ្ឌទី ៤ ទេនោះ អ្នកវិនិយោគមានវិវាទមានសិទ្ធិបញ្ជូនបណ្តឹងរបស់ខ្លួនទៅមជ្ឈត្តវិនិច្ឆ័យ អនុលោមតាមមាត្រានេះ ដោយពុំមានការជំទាស់អ្វីឡើយ ។

១២. ភាគីមួយមិនត្រូវទប់ស្កាត់អ្នកវិនិយោគមានវិវាទក្នុងការស្វែងរកវិធានការការពារជាបណ្តោះអាសន្ន ដែលមិនពាក់ព័ន្ធទៅនឹងការទូទាត់សំណង ឬដំណោះស្រាយបញ្ហាសំខាន់ៗនៃវិវាទនៅចំពោះមុខតុលាការ ឬសាលាក្តីរដ្ឋបាលរបស់ភាគីមានវិវាទ មុននឹងស្ថាប័នដំណើរការក្តី នៅចំពោះមុខវេទិកាដោះស្រាយវិវាទណាមួយដូចមានចែងក្នុងកឋាខ័ណ្ឌទី ៥ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់គេនោះឡើយ ។

១៣. ភាគីមួយមិនត្រូវផ្តល់នូវការការពារការទូត ឬដាក់បណ្តឹងអន្តរជាតិ ទាក់ទិនទៅនឹងវិវាទដែលអ្នកវិនិយោគរបស់ខ្លួន និងភាគីណាមួយផ្សេងទៀតបានយល់ព្រមបញ្ជូន ឬបានបញ្ជូនទៅមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រានេះ លើកលែងតែភាគីផ្សេងនោះមិនបានគោរព និងអនុវត្តតាមសេចក្តីសំរេចរបស់មជ្ឈត្តវិនិច្ឆ័យពាក់ព័ន្ធវិវាទនេះ ។ ការការពារជា

[២១] សំរាប់ករណីវិវាទវិនិយោគរវាងប្រទេសកូរ៉េ និងអ្នកវិនិយោគនៃភាគីផ្សេង ឬរវាងភាគីផ្សេង និងអ្នកវិនិយោគនៃប្រទេសកូរ៉េ ត្រូវចាត់ទុកថា ភាគីមានវិវាទ ពេញចិត្តបញ្ជូនវិវាទទៅវេទិកាមជ្ឈត្តវិនិច្ឆ័យ ដែលជ្រើសរើសដោយអ្នកវិនិយោគមានវិវាទ ក្នុងលក្ខខណ្ឌថា ប្រទេសកូរ៉េ និងភាគីផ្សេងទៀតពេញចិត្តបញ្ជូនវិវាទវិនិយោគនោះទៅវេទិកានោះ នៅក្នុងកិច្ចព្រមព្រៀងទ្វេភាគីដែលមានស្រាប់ ដែលក្នុងនោះប្រទេសកូរ៉េ និងភាគីផ្សេងទៀតនោះសុទ្ធតែជាភាគីចុះហត្ថលេខា ។

លក្ខណៈការទូត សំរាប់គោលបំណងនៃកថាខ័ណ្ឌនេះ នឹងមិនរាប់បញ្ចូលផងទេនូវដំណោះស្រាយការទូតក្រៅផ្លូវការ ដើម្បីគោលបំណងតែមួយគត់ក្នុងការសំរបសំរួលស្វែងរកដំណោះស្រាយចំពោះវិវាទនោះ។

១៤. សេចក្តីសំរេចដែលចេញដោយសាលាក្តីនឹងជាដំណោះស្រាយស្ថាពរ និងភ្ជាប់កាតព្វកិច្ចត្រូវតែអនុវត្តចំពោះភាគីមានវិវាទ។ សេចក្តីសំរេចនឹងពុំមានភ្ជាប់កាតព្វកិច្ចត្រូវអនុវត្ត លើកលែងរវាងភាគីមានវិវាទ និងទាក់ទិនទៅនឹងករណីជាក់លាក់ជាពិសេស។

## មាត្រា ១៩
## វិវាទរវាងភាគី

លើកលែងតែមានចែងផ្សេងពីនេះនៅក្នុងកិច្ចព្រមព្រៀងនេះ រាល់វិវាទទាក់ទិនទៅនឹងការបកស្រាយការអនុវត្តន៍ កិច្ចព្រមព្រៀងនេះ ត្រូវបានដោះស្រាយតាមរយៈនីតិវិធី និងយន្តការ ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះស្តីពីយន្តការដោះស្រាយវិវាទ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌ។

## មាត្រា ២០
## ការលើកលែងទូទៅ

១. អនុលោមទៅតាមលក្ខខណ្ឌតម្រូវដែលវិធានការទាំងនោះមិនត្រូវបានអនុវត្ត ជាមធ្យោបាយអាជ្ញាកណ្តាល ឬជាមធ្យោបាយរើសអើងមិនច្បាស់លាស់ រវាងភាគីទាំងអស់ ឬរវាងអ្នកវិនិយោគរបស់ពួកគេដែលសំរាប់លក្ខខណ្ឌដូចគ្នានោះមានឧត្តមភាព ឬការកំណត់លក្ខខណ្ឌមិនច្បាស់លាស់ចំពោះអ្នកវិនិយោគ ឬការវិនិយោគរបស់អ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀតនោះ គ្មានចំណុចណាមួយនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយថាជាការទប់ស្កាត់ចំពោះការប្រកាន់យក ឬការអនុវត្តដោយភាគីណាមួយ នូវវិធានការ :

(ក) ចាំបាច់ក្នុងការការពារសីលធម៌សាធារណៈ ឬរក្សានូវសណ្តាប់ធ្នាប់សាធារណៈ[២២]

(ខ) ចាំបាច់ក្នុងការការពារសុខភាព ឬជីវិតមនុស្ស សត្វ ឬរុក្ខជាតិ

(គ) ចាំបាច់ដើម្បីធានាបាននូវការអនុវត្តច្បាប់ ឬបទប្បញ្ញត្តិ ដែលមិនផ្ទុយពីបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះដោយរាប់បញ្ចូលទាំងបញ្ញត្តិទាំងឡាយដែលទាក់ទិនទៅនឹង :

(១) ការការពារករណីឆបោក និងក្លែងបន្លំ ដើម្បីដោះស្រាយផលប៉ះពាល់នានានៃការប្រព្រឹត្តមិនត្រឹមត្រូវនូវកិច្ចសន្យា។

---

[២២] ការលើកលែងចំពោះសណ្តាប់ធ្នាប់សាធារណៈអាចនឹងត្រូវស្នើសុំដោយភាគីមួយ តែក្នុងករណីមានការគំរាមកំហែងធ្ងន់ធ្ងរដល់ផលប្រយោជន៍ជាមូលដ្ឋានណាមួយរបស់សង្គមតែប៉ុណ្ណោះ។

(២) ការការពារឯកជនភាពរបស់បុគ្គលទាក់ទិនទៅនឹងដំណើរការ និងការផ្សព្វផ្សាយទិន្នន័យផ្ទាល់របស់បុគ្គល និងការការពារព័ត៌មានសំងាត់នៃកំណត់ត្រា និងគណនីនានារបស់បុគ្គល ។

(៣) សុវត្ថិភាព ។

(ឃ) ដែលមិនសង្គតភាពទៅនឹងមាត្រា ៣ (ប្រព្រឹត្តកម្មជាតិ) ក្នុងលក្ខខណ្ឌថា ភាពខុសគ្នានៅក្នុងប្រព្រឹត្តកម្មកើតមានក្នុងគោលបំណងដើម្បីធានានូវការកំណត់ ឬការប្រមូលពន្ធផ្ទាល់ ប្រកបដោយសមធម៌ ឬប្រសិទ្ធភាព[២៣] ទាក់ទិនទៅនឹងការវិនិយោគ ឬអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត ។

(ង) ដែលត្រូវបានកំណត់សំរាប់ការការពាររតនសម្បត្តិជាតិដែលមានតំលៃសិល្បៈ ប្រវត្តិសាស្ត្រ ឬ បូរាណវិទ្យា ឬ

(ច) ទាក់ទិនទៅនឹងការអភិរក្សធនធានធម្មជាតិដែលអាចហិនហោច ប្រសិនបើវិធានការនោះត្រូវបានប្រកាន់យកប្រកបដោយប្រសិទ្ធភាព តាមរយៈការភ្ជាប់ជាមួយគ្នាទៅនឹងការកំហិតលើផលិតកម្ម ឬការប្រើប្រាស់ក្នុងស្រុក ។

២. រហូតដល់ពេលនេះ បណ្តាវិធានការដែលប៉ះពាល់ដល់ការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ មានទំនាក់ទំនងទៅនឹងកថាខ័ណ្ឌទី ២ (បទប្បញ្ញត្តិក្នុងស្រុក) នៃឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុរបស់ GATS ត្រូវបញ្ចូលទៅក្នុង និងបង្កើត បានជាផ្នែកមួយទាំងស្រុងនៃកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងផ្នែកវិសោធនកម្មដែលបានធ្វើឡើងផងដែរ (Mutatis Mutandis) ។

## មាត្រា ២១
## ការលើកលែងចំពោះសន្តិសុខ

១. គ្មានចំណុចណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយថា :

(ក) ជាការតម្រូវឱ្យភាគីមួយផ្តល់នូវព័ត៌មានណាមួយ ដែលខ្លួនយល់ថា ការបញ្ចេញនូវព័ត៌មានទាំងនោះមានលក្ខណៈផ្ទុយទៅនឹងផលប្រយោជន៍សំខាន់ផ្នែកសន្តិសុខរបស់ខ្លួនឡើយ ឬ

(ខ) ជាការទប់ស្កាត់ភាគីណាមួយមិនឱ្យចាត់វិធានការផ្សេងៗ ដែលខ្លួនយល់ថា ជាការចាំបាច់ក្នុងកិច្ចការពារនូវផលប្រយោជន៍សំខាន់ៗផ្នែកសន្តិសុខរបស់ខ្លួននោះឡើយ :

[២៣] សំរាប់គោលបំណងនៃកថាខ័ណ្ឌនេះ ចំណុចសំគាល់ជើងទំព័រទី ៦ នៃមាត្រា ១៤ នៃ GATS ត្រូវបានបញ្ចូលទៅក្នុង និងបង្កើតបានជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងនេះ និងទាំងផ្នែកវិសោធនកម្មទាំងឡាយរបស់វា ។

ពាក់ព័ន្ធនឹងជំនួញអាវុធយុទ្ធភ័ណ្ឌ និងឧបករណ៍ធ្វើសង្គ្រាមផ្សេងៗ ក៏ដូចជា ជំនួញលើទំនិញ និងសំភារៈផ្សេងៗ ឬដែលមានការទាក់ទងជាមួយនឹងការផ្គត់ផ្គង់សេវាកម្ម ដែលធ្វើឡើងដោយផ្ទាល់ ឬដោយប្រយោល ក្នុងគោលបំណង បំរើឱ្យការផ្គត់ផ្គង់ ឬ ឧបត្ថម្ភដល់មូលដ្ឋានយោធា ។

២. ការចាត់វិធានការក្នុងកាលៈទេសៈមានសង្គ្រាម ឬស្ថានភាពអាសន្នផ្សេងៗសំរាប់ទំនាក់ទំនងក្នុងស្រុក ឬ អន្តរជាតិ ។

៣. ពាក់ព័ន្ធនឹងសារធាតុបរមាណូ និងនុយក្លេអ៊ែរ ឬសារធាតុដែលបង្កើតឡើងចេញពីសារធាតុទាំងនេះ ។

៤. ការចាត់វិធានការដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំខាន់ៗ រាប់បញ្ចូលទាំងប្រព័ន្ធគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធថាមពល និងទឹក ដើម្បីចៀសឱ្យផុតពីការប៉ុនប៉ង ធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធទាំងនេះ អសកម្ម ឬ ខូចខាត ។

(គ) ជាការហាមឃាត់ភាគីមួយ មិនឱ្យចាត់វិធានការណាមួយដែលវិធានការនោះ ស្របទៅតាមកាតព្វកិច្ច របស់ខ្លួន ដូចមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិស្តីពីការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិឡើយ ។

២. គណៈកម្មាធិការប្រតិបត្តិ ត្រូវទទួលបាននូវការជូនដំណឹងយ៉ាងគ្រប់គ្រាន់ស្តីពីវិធានការដែលចាត់ឡើង ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ១ (ខ) និង (គ) និងអំពីការបញ្ឈប់នូវវិធានការទាំងនោះផងដែរ ។

## មាត្រា ២២

## ពន្ធដារ

គ្មានចំណុចណាមួយក្នុងកិច្ចព្រមព្រៀងនេះ នឹងធ្វើឱ្យប៉ះពាល់ទៅដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីណាមួយ ដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងស្តីពីសារពើពន្ធ ដែលភាគីនោះជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងនោះឡើយ ។ ក្នុងករណីកង្វះសង្គតភាពរវាងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀងណាមួយដូចគ្នានេះ កិច្ចព្រមព្រៀងដដែលនោះ ត្រូវយកមកធ្វើជាសំអាងក្នុងការបកស្រាយត្រង់ចំណុចដែលមិនមានសង្គតភាពនោះ ។

## មាត្រា ២៣

## ទំនាក់ទំនងជាមួយនឹងកិច្ចព្រមព្រៀងផ្សេងៗ

១. គ្មានចំណុចណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយថា ជាការដកហូតនូវសិទ្ធិ ឬកាតព្វកិច្ចណាមួយរបស់ភាគីមួយដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងអន្តរជាតិដែលភាគីនោះជាភាគីហត្ថលេខីនោះឡើយ ។

២. ប្រសិនបើកាតព្វកិច្ចអន្តរជាតិនាពេលបច្ចុប្បន្ន ឬត្រូវបានបង្កើតឡើងនៅពេលខាងមុខ រវាងភាគីបន្ថែមលើកិច្ចព្រមព្រៀងនេះ ដែលនាំឱ្យអ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀត និងការវិនិយោគរបស់អ្នកវិនិយោគនៃភាគីណាមួយផ្សេងទៀតនោះ ទទួលបាននូវប្រព្រឹត្តិកម្មដែលមានភាពអនុគ្រោះច្រើនជាងអ្វីដែលកិច្ចព្រមព្រៀងនេះបានផ្តល់ជូននោះ សិទ្ធិនោះនឹងមិនត្រូវបានប៉ះពាល់ដោយកិច្ចព្រមព្រៀងនេះឡើយ ។

## មាត្រា ២៤
## ការរៀបចំស្ថាប័ន

ស្ថាប័នដែលមានចែងក្នុងមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌត្រូវតាមដាន គ្រប់គ្រង សំរបសំរួល និងពិនិត្យ លើការអនុវត្តកិច្ចព្រមព្រៀងនេះ ប្រសិនបើយល់ថាសមស្រប ។

## មាត្រា ២៥
## ការពិគ្រោះយោបល់

ភាគីទាំងអស់ព្រមព្រៀងធ្វើការពិគ្រោះប្រឹក្សាគ្នាទៅវិញទៅមក តាមការស្នើសុំរបស់ភាគីណាមួយ អំពីបញ្ហានានា ដែលទាក់ទិនទៅនឹងការវិនិយោគក្រោមកិច្ចព្រមព្រៀងនេះ ឬក្រៅពីនេះ ដែលប៉ះពាល់ទៅលើការអនុវត្តកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២៦
## ការពិនិត្យ និងសេរីភាវូបនីយកម្មនាពេលអនាគត

១. ស្ថាប័នដែលមានចែងក្នុងមាត្រា ៥.៣ នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ត្រូវពិនិត្យលើការអនុវត្តកិច្ចព្រមព្រៀងនេះ ។

២. ភាគីទាំងអស់នៃកិច្ចព្រមព្រៀងនេះ នឹងធ្វើការពង្រឹងពង្រីកនូវសេរីភាវូបនីយកម្មឱ្យកាន់តែមានវិសាលភាពធំធេងឡើងតាមរយៈកិច្ចចរចានាពេលអនាគត ក្នុងគោលដៅដើម្បីឈានទៅសំរេចការកាត់បន្ថយ ឬការលុបបំបាត់នូវការដាក់កំហិតផ្សេងៗទៀតនៅសេសសល់ដែលពុំទាន់បានលើកលែងដូចមានកំណត់ ស្របតាមមាត្រា ៩ (ស្តីពីការបំរុងទុក) ដើម្បីជាប្រយោជន៍ដល់គ្នាទៅវិញទៅមក និងដើម្បីធានាឱ្យមានជារួមនូវតុល្យភាពនៃសិទ្ធិ និងកាតព្វកិច្ចនានា ។

## មាត្រា ២៧
## កម្មវិធីការងារ

ភាគីទាំងឡាយត្រូវចូលរួមនៅក្នុងកិច្ចពិភាក្សាលើបញ្ហានានាដូចខាងក្រោម ៈ

(ក) មាត្រា ៤ (ប្រព្រឹត្តិកម្មជាតិមានភាពអនុគ្រោះបំផុត)

(ខ) ការបញ្ចូលធាតុបន្ថែម TRIMs ទៅក្នុងមាត្រា ៦ (ការតម្រូវឱ្យបំពេញកាតព្វកិច្ច)

(គ) តារាងនៃបញ្ជីស្តីពីការបំរុងទុកនៃកិច្ចព្រមព្រៀងនេះ

[23] For the purpose of this subparagraph, footnote 6 of Article XIV of the GATS is incorporated into and forms an integral part of this Agreement, *mutatis mutandis*.



CERTIFIED COPY DEPUTY SECRETARY GENERAL THE ASEAN SECRETARIAT asean

(f) relating to the conservation of exhaustible natural resources if such measures are made effective in conjunction with restrictions on domestic production or consumption.

2. Insofar as measures affecting the supply of financial services are concerned, paragraph 2 (Domestic Regulation) of the Annex on Financial Services of the GATS shall be incorporated into and form an integral part of this Agreement, *mutatis mutandis*.

**Article 21**
**Security Exceptions**

1. Nothing in this Agreement shall be construed:

(a) to require a Party to furnish any information, the disclosure of which it considers contrary to its essential security interests; or

(b) to prevent a Party from taking any actions which it considers necessary for the protection of its essential security interests:

(i) relating to the traffic in arms, ammunition and implements of war and to such traffic in other goods and materials or relating to the supply of services as carried on, directly or indirectly, for the purpose of supplying or provisioning a military establishment;

(ii) taken in time of war or other emergency in domestic or international relations;



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

(iii) relating to fissionable and fusionable materials or the materials from which they are derived;

(iv) taken to protect critical public infrastructures, including communication, power and water infrastructures, from deliberate attempts intended to disable or degrade such infrastructures; or

(c) to prevent a Party from taking any action in pursuance of its obligations under the United Nations Charter for the maintenance of international peace and security.

2. The Implementing Committee shall be informed to the fullest extent possible of measures taken under paragraphs 1(b) and (c) and of their termination.

## Article 22
## Taxation

Nothing in this Agreement shall affect the rights and obligations of any Party under any tax agreement to which the Party is a party. In the event of any inconsistency between this Agreement and any such agreement, that agreement shall prevail to the extent of the inconsistency.

## Article 23
## Relation to Other Agreements

1. Nothing in this Agreement shall be construed to derogate from any right or obligation of a Party under international agreements to which the Parties are party.



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

2. If the international obligations existing at present or established hereafter between the Parties in addition to this Agreement, result in a position entitling investors of any other Party and investments by investors of any other Party to treatment more favourable than is provided for by this Agreement, such position shall not be affected by this Agreement.

**Article 24**
**Institutional Arrangements**

The institutions as provided for in Article 5.3 of the Framework Agreement shall oversee, supervise, coordinate and review, as appropriate, the implementation of this Agreement.

**Article 25**
**Consultations**

The Parties agree to consult each other at the request of any Party on any matter relating to investments covered by this Agreement, or otherwise affecting the implementation of this Agreement.

**Article 26**
**Review and Future Liberalisation**

1. The institutions as provided for in Article 5.3 of the Framework Agreement shall review the implementation of this Agreement.



CERTIFIED COPY DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT asean

2. The Parties will, through future negotiations, further deepen liberalisation with a view to reaching the reduction or elimination of the remaining restrictions scheduled in conformity with Article 9 (Reservations), on a mutually advantageous basis and ensuring an overall balance of rights and obligations.

**Article 27**
**Work Programme**

1. The Parties shall enter into discussions on:

(a) Article 4 (Most-Favoured-Nation Treatment);

(b) TRIMs-plus elements to Article 6 (Performance Requirements);

(c) Schedules of Reservations to this Agreement;

(d) Procedures for modification of Schedules of Reservations that will apply at the date of entry into force of the Schedules of Reservations to this Agreement;

(e) Annex on Expropriation and Compensation;

(f) Annex on Taxation and Expropriation; and

(g) Article 18 (Investment Dispute Settlement between a Party and an Investor of any other Party).

2. The Parties shall conclude the discussions referred to in paragraph 1, within five years from the date of entry into force of this Agreement unless the Parties otherwise agree.

These discussions shall be overseen by the Implementing Committee established under Article 5.3 of the Framework Agreement.

3. Schedules of Reservations to this Agreement referred to in paragraph 1 shall enter into force on a date agreed to by the Parties.

4. Notwithstanding anything to the contrary in this Agreement, Article 3 (National Treatment), Article 4 (Most-Favoured-Nation Treatment), Article 7 (Senior Management and Boards of Directors), Article 9 (Reservations), and in the case of the Lao People's Democratic Republic Article 6 (Performance Requirements), shall not apply until the Parties' Schedules of Reservations to this Agreement have entered into force in accordance with paragraph 3.

## Article 28
## Annexes and Future Instruments

This Agreement shall include:

(a) the Annexes and the contents therein which shall form an integral part of this Agreement; and

(b) all future legal instruments agreed pursuant to this Agreement.

## Article 29
## Amendments

The provisions of this Agreement may be modified through amendments mutually agreed upon in writing by the Parties.

CERTIFIED COPY DEPUTY SECRETARY GENERAL THE ASEAN SECRETARIAT asean

## Article 30
## Depositary

For the ASEAN Member Countries, this Agreement shall be deposited with the Secretary-General of ASEAN, who shall promptly furnish a certified copy thereof, to each ASEAN Member Country.

## Article 31
## Entry into Force

1. This Agreement shall enter into force on the first day of the second month following the latter date on which at least one ASEAN Member Country and Korea have notified all the other Parties in writing of the completion of their internal procedures.

2. A Party shall, upon the completion of its internal procedures for the entry into force of this Agreement, notify all the Parties in writing.

3. Where a Party is unable to complete its internal procedures for the entry into force of this Agreement by the date as set out in paragraph 1, this Agreement shall come into force for that Party, 30 days after the date on which that Party has notified all the other Parties in writing of the completion of its internal procedures. The Party concerned, however, shall be bound by the same terms and conditions of this Agreement, including any further commitments that may have been undertaken by the other Parties under this Agreement by the time of such notification, as if it had notified all the other Parties in writing of the completion of its internal procedures before the date of entry into force of this Agreement.



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

**IN WITNESS WHEREOF,** the undersigned, being duly authorised thereto, have signed this Agreement on Investment under the Framework Agreement on Comprehensive Economic Cooperation among the Governments of the Member Countries of the Association of Southeast Asian Nations and the Republic of Korea.

**DONE** at Jeju-do, Republic of Korea, this 2nd day of June 2009, in duplicate copies in the English language.

For the Government of Brunei Darussalam:

**LIM JOCK SENG**
Second Minister of Foreign Affairs and Trade

For the Government of the Republic of Korea:

**KIM JONG-HOON**
Minister for Trade

For the Royal Government of Cambodia:

**CHAM PRASIDH**
Senior Minister and Minister of Commerce

For the Government of the
Republic of Indonesia:

**MARI ELKA PANGESTU**
Minister of Trade

For the Government of the Lao
People's Democratic Republic:

**NAM VIYAKETH**
Minister of Industry and
Commerce

For the Government of
Malaysia:

**DATUK MUSTAPA**
**MOHAMED**
Minister of International Trade
and Industry



CERTIFIED COPY
DEPUTY SECRETARY-GENERAL, THE ASEAN SECRETARIAT
asean

For the Government of the
Union of Myanmar:

**U SOE THA**
Minister for National Planning
and Economic Development

For the Government of the
Republic of the Philippines:

**PETER B. FAVILA**
Secretary of Trade and
Industry

For the Government of the
Republic of Singapore:

**LIM HNG KIANG**
Minister for Trade and Industry



CERTIFIED COPY
asean

For the Government of the
Kingdom of Thailand:

**PORNTIVA NAKASAI**
Minister of Commerce

For the Government of the
Socialist Republic of Viet Nam:

**VU HUY HOANG**
Minister of Industry and Trade



CERTIFIED COPY
DEPUTY SECRETARY GENERAL, THE ASEAN SECRETARIAT

## Annex 1
## Approval in Writing

Where specific approval in writing is required for covered investments by a Party's domestic laws, regulations and national policies, that Party shall:

(a) inform all the other Parties through the ASEAN Secretariat of the contact details of its competent authority responsible for granting such approval;

(b) in the case of an incomplete application, identify and notify the applicant in writing within one month from the date of receipt of such application of all the additional information that is required;

(c) inform the applicant in writing that the investment has been specifically approved or denied within four months from the date of receipt of complete application by the competent authority; and

(d) in the case an application is denied, inform the applicant in writing of the reasons for such denial. The applicant shall have the opportunity of submitting, at that applicant's discretion, a new application.



CERTIFIED COPY

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៥២១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យូ សាង** (YOO SANG) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៨៦ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ ដោយប្តូរឈ្មោះជា **យូ សំណាង** (YOO SAM NANG) ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពរល. ១០០៦.៥២៩*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០*

លេខ:៤៨៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ជីនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៥៤៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ជុង សឺងបេ** (JUNG SEUNG BAE) ជនជាតិកូរ៉េ សញ្ជាតិកូរ៉េ កើតថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៦១ នៅសាធារណរដ្ឋកូរ៉េ ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ព.រ.ល.១០០៦.៥៣០*

លេខៈ៤៨១ ច.ល
[illegible]ចម្លងចែក
[illegible]រាជធានីភ្នំពេញ.ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០*

[illegible]រាជរដ្ឋាភិបាល

[illegible] ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៥៣០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ជូនលោក **អាសីឌីន បេសឆាអ៊ូជ** (AZEDINE BESCHAOUCH) ជនជាតិទុយនីស៊ី សញ្ជាតិទុយនីស៊ី កើតថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៣៨ នៅក្រុងទុយនីស ប្រទេសទុយនីស៊ី ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១០*

*៣រល.១០០៦.៥៣៩*

លេខ:៥៩៧ ច.ល
ចម្លងចេញពីច្បាប់ដើម
បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ធ្វើនៅភ្នំពេញ ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៦១០/៥៣៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **មូន ចូសេហ្វ ជី.អេល** (MOONS JOZEF J.L) ជនជាតិបែលហ្ស៊ិក សញ្ជាតិបែលហ្ស៊ិក កើតថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៦២ នៅទីក្រុងធូនហ៊ុត ប្រទេសបែលហ្ស៊ិក ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១០*

*ពសរ.១០០៦.៥៤៦*

**លេខ: ៤៧៣ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០១០
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**យុន ជិនអេន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៨៣ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែសម្រួល

មាត្រា៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៤ថ្មី នៃអនុក្រឹត្យលេខ ៦៨ នអនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា៤ នៃអនុក្រឹត្យលេខ ៨៨ នអនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៣០ខែកក្កដាឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដែលសរសេរកាត់ថា **អ.ក.គ.ដ.**។

## ជំពូកទី២

## បេសកកម្ម តួនាទីនិងភារកិច្ចរបស់ អ.ក.គ.ដ.

**មាត្រា២.-**

**អ.ក.គ.ដ.** មានបេសកកម្មផ្តួចផ្តើមលើកសំណើ និងរៀបចំគោលនយោបាយក្នុងវិស័យដីធ្លីស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងទៅតាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា៣.-**

**អ.ក.គ.ដ.** មានតួនាទីជាសេនាធិការ និងជាអង្គភាពប្រតិបត្តិ នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានភារកិច្ចដូចតទៅ ៖

១-ផ្តួចផ្តើមគំនិតសិក្សា រៀបចំ និងអភិវឌ្ឍគោលនយោបាយដីធ្លីទូលំទូលាយ ហៅកាត់ " សៀវភៅសដីធ្លី " ដើម្បីតម្រង់ទិសលើការងាររដ្ឋបាលដីធ្លី ការងាររៀបចំដែនដី និងការងារបែងចែកដីធ្លី ឲ្យមានតម្លាភាព និងមានប្រសិទ្ធភាព។

២-ធ្វើការតាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយដីធ្លី។

៣-សម្របសម្រួល និងលើកសំណើជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី អំពីការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តនានាសម្រាប់គ្រប់គ្រង

អនុវត្តកម្មវិធី និងគោលនយោបាយដីធ្លីឲ្យមានប្រសិទ្ធភាព។

៤-លើកសំណើជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យនិងសម្រេចលើ៖

-ការតែងតាំង ការដំឡើងឋានៈ ឋានន្តរសក្តិ ការផ្ទេរភារកិច្ច ឬការដកមុខតំណែង មន្ត្រីបុគ្គលិក របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ការជួលទីប្រឹក្សាជាតិ និង/ឬអន្តរជាតិ តាមតម្រូវការចាំបាច់

-ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ក្រុមជំនួយការបច្ចេកទេស និងលេខាធិការមួយចំនួន ជាជំនួយការក្នុងការងារប្រចាំថ្ងៃ និង

-ផែនការ សកម្មភាព ការងារ ផែនការថវិកាប្រចាំឆ្នាំ មានជាអាទិ៍ ការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយ អំពីគោលនយោបាយ និងក្របខណ្ឌគតិយុត្ត ដែលរាជរដ្ឋាភិបាល និងក្រុមប្រឹក្សាគោលនយោបាយ ដីធ្លីបានដាក់ចេញ។

៥-គ្រប់គ្រងរាល់ធនធានរបស់អគ្គលេខាធិការដ្ឋាន រួមមាន ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស សម្ភារៈ ព្រមទាំងមធ្យោបាយបំពេញការងារ។

៦-ជួយការងារដល់ក្រុមការងារដែលបានបង្កើតដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

៧-ធ្វើរបាយការណ៍បូកសរុបវាយតម្លៃ ពីលទ្ធផលនៃការអនុវត្តកម្មវិធីគោលនយោបាយកំណែទម្រង់ដីធ្លីជាទៀងទាត់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងរាជរដ្ឋាភិបាល តាមរយៈប្រធានក្រុមប្រឹក្សា គោលនយោបាយដីធ្លី។

៨-ធ្វើកំណត់ហេតុនៃកិច្ចប្រជុំ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងកិច្ចប្រជុំរបស់ក្រុមការងារ ដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានបង្កើតឡើង។

៩-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធ និងការគ្រប់គ្រង

**មាត្រា៤.-**

**អ.គ.គ.ដ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។

អគ្គលេខាធិការនៃ **អ.គ.គ.ដ.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**មាត្រា៥.-**

**អ.គ.គ.ដ.** មានរចនាសម្ព័ន្ធដូចតទៅ៖

១- ផ្នែកគោលនយោបាយ

២- ផ្នែកបទដ្ឋានគតិយុត្ត

៣-ផ្នែករដ្ឋបាល ពង្រឹងស្ថាប័ន និងហិរញ្ញវត្ថុ

អង្គការលេខរបស់ **អ.ភ.គ.ដ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦.-**

ផ្នែកនីមួយៗដឹកនាំដោយប្រធានផ្នែក ១ (មួយ) រូប អមដោយអនុប្រធានផ្នែកមួយចំនួនតាមការចាំបាច់។

ប្រធានផ្នែកនីមួយៗមានឋានៈស្មើនឹងប្រធាននាយកដ្ឋាន។

អនុប្រធានផ្នែកនីមួយៗមានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន។

ផ្នែកនីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា៧.-**

**អ.ភ.គ.ដ.** មានមន្ត្រីបម្រើការងារមកពីក្របខណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ **អ.ភ.គ.ដ.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឲ្យមកបម្រើការងារបាន។

**មាត្រា៨.-**

**អ.ភ.គ.ដ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៤
## ភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា៩.-**

ផ្នែកគោលនយោបាយ មានភារកិច្ច ដូចតទៅ ៖

-រៀបចំ តាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយដីធ្លីទូលំទូលាយ ហៅថា " សៀវភៅសដីធ្លី "

-ធ្វើការវិភាគគោលនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់ក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងវិស័យដីធ្លី ពិសេសពីប្រជាពលរដ្ឋដែលមានផលប្រយោជន៍លើគោលនយោបាយដីធ្លី

-លើកសំណើគោលនយោបាយកំណែទម្រង់ដីធ្លី ទស្សនាទាន ផែនការកម្ម ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យ និងសម្រេច

-ផ្តួចផ្តើម និងលើកសំណើផែនការយុទ្ធសាស្ត្រនៃការអនុវត្តគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលដាក់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីពិនិត្យ និងសម្រេច

-ធ្វើរបាយការណ៍ពីសកម្មភាព និងលទ្ធផលការងារដែលផ្នែកសម្រេចបានផ្តល់ជូនផ្នែករដ្ឋបាល ពង្រឹង ស្ថាប័ន និងហិរញ្ញវត្ថុ ដើម្បីបូកសរុបជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា១០.-**

ផ្នែកបទដ្ឋានគតិយុត្ត មានភារកិច្ច ដូចតទៅ ៖

-ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា សម្រាប់ដំណើរការការងារគ្រប់គ្រងប្រើប្រាស់ និងបែងចែកដីធ្លី ប្រកបដោយប្រសិទ្ធភាព

-លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី

-តាមដាន វាយតម្លៃ និងលើកសំណើយុទ្ធសាស្ត្រក្នុងការអនុវត្ត និងអភិវឌ្ឍនីតិវិធីដើម្បីជំរុញ និងធានា និរន្តរភាព ប្រសិទ្ធភាព តម្លាភាព និងសមធម៌នូវការងារចុះបញ្ជីដីធ្លី ការងាររៀបចំ ដែនដី នគរូបនីយកម្ម និងការងារបែងចែកដីធ្លី

-ធ្វើរបាយការណ៍ពីសកម្មភាព និងលទ្ធផលការងារដែលផ្នែកសម្រេចបាន

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា១១.-**

ផ្នែករដ្ឋបាល ពង្រឹងស្ថាប័ន និងហិរញ្ញវត្ថុ មានភារកិច្ច ដូចតទៅ ៖

ក. ការងាររដ្ឋបាល ៖

-គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបពីសកម្មភាព និងលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ដីធ្លី របស់រាជរដ្ឋាភិបាលដាក់ជូនសម័យប្រជុំក្រុមប្រឹក្សាគោលនយោបាយដីធ្លីពិនិត្យ និងដើម្បីមានទិសណែនាំអនុវត្តបន្ត

-រៀបចំ និងសម្រួល ធ្វើលេខាធិការកត់ត្រាកិច្ចប្រជុំ ឬសិក្ខាសាលា និងការពិភាក្សារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី រួមទាំងក្រុមការងារដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានបង្កើតឡើង

-ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-រក្សាទុកឯកសាររបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី និង **អ.ក.គ.ដ.**

-សម្របសម្រួលជាមួយក្រសួងស្ថាប័នជំនាញ ដើម្បីទទួលបានព័ត៌មាន និងកម្មវិធីនានាសម្រាប់សិក្សាស្វែងយល់របស់ក្រុមការងារដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានបង្កើតឡើង និងរបស់ទីប្រឹក្សា ឬអ្នកជំនាញការជាតិ អន្តរជាតិដែលនៅអម **អ.ក.គ.ដ.**។

ខ. ការងារពង្រឹងស្ថាប័ន ៖

-ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធដើម្បីជំរុញឲ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ ដើម្បីបំពេញការងារក្នុង **អ.ក.គ.ដ.**

-លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅទាក់ទងទៅនឹងការបញ្ជ្រាបទស្សនៈយល់ដឹងឲ្យបានទូលំទូលាយអំពីគោលនយោបាយ និងក្របខណ្ឌគតិយុត្តនានាទាក់ទងនឹងដីធ្លី ដែលរាជរដ្ឋាភិបាល ក៏ដូចជាក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានដាក់ចេញ។

គ. ការងារហិរញ្ញវត្ថុ ៖

-កសាងគម្រោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តថវិកានៃ **អ.ក.គ.ដ.**

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌនៃ **អ.ក.គ.ដ.**

-រៀបចំផែនការចំណាយនានាសម្រាប់ផ្នែកផ្សេងៗនៃ **អ.ក.គ.ដ.**

-លើកសំណើចំណាយលើសម្ភារៈសម្រាប់គាំទ្រដល់ដំណើរការនៃ **អ.ក.គ.ដ.**

-ធ្វើរបាយការណ៍ចំណាយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ សម្រាប់ **អ.ក.គ.ដ.**

-រក្សាឲ្យបានត្រឹមត្រូវនូវរាល់ឯកសារសម្រាប់ធ្វើសវនកម្ម

-សហការជាមួយនាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសម្រួលដល់ការងាររៀបចំ និងការចំណាយថវិកា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិនៃអនុក្រឹត្យលេខ៩៦អនក្រ.បក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៩៣. អនក្រ.បក ចុះថ្ងៃទី ០៣. ខែសីហា ឆ្នាំ២០១០**
**រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី**



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៧៤ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២០៩/១២១១ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ ដែលសរសេរកាត់ថាអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន

**មាត្រា២.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- ជាសេនាធិការ ដើម្បីធ្វើការសម្របសម្រួលរាល់ការងារដឹកនាំបញ្ជា ការងារប្រតិបត្តិការ ការងារផ្គត់ផ្គង់ និងការងារសហប្រតិបត្តិការអន្តរជាតិ របស់ **គ.ជ.ស.ស.**
- រៀបចំ និងអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែង
- ស្រាវជ្រាវ ប្រមូលផ្តុំ និងរៀបចំតាក់តែងច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ដែលត្រូវការចាំបាច់សម្រាប់ប្រើប្រាស់ នៅក្នុងការគ្រប់គ្រង និងអភិបាលកិច្ចសន្តិសុខលម្ហសមុទ្រ
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពលើសភាពការណ៍សន្តិសុខជាប្រចាំ
- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការប្រើប្រាស់កម្លាំង សម្ភារៈ និងធនធានផ្សេងៗ នៅក្នុងការបំពេញការងារ និងកិច្ចប្រតិបត្តិការរបស់ **គ.ជ.ស.ស.**
- កសាង និងអភិវឌ្ឍ វិធានការសន្តិសុខចាំបាច់ទាំងឡាយរបស់ **គ.ជ.ស.ស.** ដើម្បីបង្ការ ទប់ស្កាត់ ការពារ និងធ្វើអន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ចំពោះការរំលោភបំពាន និងបទល្មើសទាំងឡាយ ព្រមទាំងត្រៀមលក្ខណៈឆ្លើយតបនឹងតម្រូវការនៃការសង្គ្រោះពេលមានគ្រោះមហន្តរាយ និងការការពារបរិស្ថាន

- កសាង និងអភិវឌ្ឍ ផែនការកសាងសមត្ថភាពរបស់សមត្ថកិច្ចទាំងឡាយដែលនៅក្រោមការទទួលខុសត្រូវរបស់ **គ.ជ.ស.ស.** រួមមានការបណ្តុះបណ្តាលធនធានមនុស្ស ការគ្រប់គ្រងគ្រឿងបំពាក់ ការងារសតិអារម្មណ៍ និងការចូលរួមក្នុងវិស័យសន្តិសុខលម្ហសមុទ្រ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ
- សម្របសម្រួលកិច្ចសហប្រតិបត្តិការ ជាមួយអង្គការសហប្រជាជាតិ បណ្តាប្រទេស និងស្ថាប័នអន្តរជាតិនានា លើវិស័យសន្តិសុខលម្ហសមុទ្រ
- ស្វែងរកការឧបត្ថម្ភគាំទ្រ ពីសំណាក់សហគមន៍អន្តរជាតិ បណ្តាប្រទេស ដៃគូសន្តិសុខ និងពីប្រភពផ្សេងៗទៀត ដើម្បីពង្រឹងនិរន្តរភាពរបស់ **គ.ជ.ស.ស.**
- រៀបចំផែនការថវិកាប្រចាំឆ្នាំរបស់ **គ.ជ.ស.ស.**
- រៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញ របស់ **គ.ជ.ស.ស.**
- បូកសរុបលទ្ធផលការងាររបស់ **គ.ជ.ស.ស.** ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែល **គ.ជ.ស.ស.** ប្រគល់ជូន ។

**មាត្រា៣.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ធ្វើការងារនៅទីបញ្ជាការគោល និងនៅទីបញ្ជាការជួរមុខ ។

អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានសិទ្ធិប្រើប្រាស់ត្រារបស់ **គ.ជ.ស.ស.** ។

## ជំពូកទី៣

## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៤.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ដឹកនាំដោយអគ្គលេខាធិការ ០១ រូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់។

អគ្គលេខាធិការ **គ.ជ.ស.ស.** គ្រប់គ្រង ចាត់ចែង និងដឹកនាំការងាររបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**។

អគ្គលេខាធិការ **គ.ជ.ស.ស.** ស្នើសុំជ្រើសរើស តែងតាំង ឬផ្លាស់ប្តូរមុខតំណែង មន្ត្រី បុគ្គលិករបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ដោយមានការសហការជាមួយក្រសួង ស្ថាប័នសាមី។

អគ្គលេខាធិការ **គ.ជ.ស.ស.** ជាអាណាប័កផ្ទេរសិទ្ធិ ។

**មាត្រា៥.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានរចនាសម្ព័ន្ធដូចតទៅ ៖

- នាយកដ្ឋានរដ្ឋបាល

- នាយកដ្ឋានផែនការ
- នាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការ
- នាយកដ្ឋានផ្គត់ផ្គង់
- នាយកដ្ឋាននីតិកម្ម

អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា៦.-**

នាយកដ្ឋាននីមួយៗ របស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** ត្រូវដឹកនាំដោយប្រធាននាយក-ដ្ឋាន ០១ រូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

នាយកដ្ឋាននីមួយៗ មានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធាន **គ.ជ.ស.ស.**។

**មាត្រា៧.-**

អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.** មានមន្ត្រីបម្រើការងារ មកពីក្របខណ្ឌកងយោធពលខេមរភូមិន្ទ ក្របខណ្ឌនគរបាលជាតិ និងក្របខណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការដ្ឋានអាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឱ្យមកបំពេញការងារបាន។

## ជំពូកទី៤
## តួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ

**មាត្រា៨.-**

នាយកដ្ឋានរដ្ឋបាល មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- សម្របសម្រួលផ្នែករដ្ឋបាលរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន
- រៀបចំនិងគ្រប់គ្រងដំណើរការនៃលិខិតបទដ្ឋានទាំងអស់
- គ្រប់គ្រងនិងអនុវត្ត ការងារបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**
- គ្រប់គ្រងការងារហ្វឹកហ្វឺន អប់រំ និងបណ្តុះបណ្តាលធនធានមនុស្សក្នុង និងក្រៅប្រទេស
- បូកសរុបរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**
- រៀបចំកិច្ចប្រជុំ សន្និបាត សិក្ខាសាលាទាំងឡាយ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **គ.ជ.ស.ស.** ប្រគល់ជូន ។

**មាត្រា៩.-**

នាយកដ្ឋានផែនការ មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- សិក្សា ស្រាវជ្រាវ និងលើកស្ទួយការយល់ដឹងអំពីសន្តិសុខលម្ហសមុទ្រ
- ធ្វើបច្ចុប្បន្នភាពលើសភាពការណ៍សន្តិសុខនៅក្នុងលម្ហសមុទ្រនិងតំបន់ជាប់មាត់សមុទ្រ
- រៀបចំ និងអភិវឌ្ឍគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរយៈពេលខ្លី មធ្យម និងវែង ដើម្បីបង្ការ ទប់ស្កាត់ ការពារ និងធ្វើអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ចំពោះការរំលោភបំពាន និងបទល្មើសទាំងឡាយ ព្រមទាំងត្រៀមលក្ខណៈដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការសង្គ្រោះ ពេលមានគ្រោះមហន្តរាយនិងការការពារបរិស្ថាន
- រៀបចំផែនការជាក់លាក់របស់ **គ.ជ.ស.ស.** អំពីការគ្រប់គ្រង ការចាត់ចែង ការសម្របសម្រួល ការទទួលខុសត្រូវ លើកម្លាំងសមត្ថកិច្ចពាក់ព័ន្ធទាំងឡាយ
- ជាចំណុចកណ្តាល នៅក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន បណ្តាប្រទេស ដៃគូសន្តិសុខ អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិនានា ដើម្បីស្វែងរកការឧបត្ថម្ភគាំទ្រសម្រាប់ការអភិវឌ្ឍសមត្ថភាព កម្លាំងនិងសម្ភារៈ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **គ.ជ.ស.ស.** ប្រគល់ជូន។

**មាត្រា១០.-**

នាយកដ្ឋានគ្រប់គ្រងប្រតិបត្តិការ មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- អនុវត្តវិធានការសម្របសម្រួល នៃការប្រើប្រាស់កម្លាំង សម្ភារៈ និងធនធានផ្សេងៗ សម្រាប់កិច្ចប្រតិបត្តិការទាំងឡាយរបស់ **គ.ជ.ស.ស.** នៅក្នុងបេសកកម្មការពារសន្តិសុខ និងអនុវត្តច្បាប់
- ក្តាប់និងតាមដានជាប្រចាំ រាល់សភាពការណ៍ដែលកើតមាននៅក្នុងតំបន់ដែល **គ.ជ.ស.ស.** ទទួលខុសត្រូវ
- គ្រប់គ្រងនិងអនុវត្តការងារព័ត៌មានចារកម្ម
- ធ្វើបទបញ្ជាប្រតិបត្តិការសម្រាប់បេសកកម្មនីមួយៗ
- គ្រប់គ្រងកិច្ចប្រតិបត្តិការ និងការបំពេញបេសកកម្ម របស់កម្លាំងសមត្ថកិច្ច **គ.ជ.ស.ស.**

- ធ្វើការបូកសរុបវាយតម្លៃ លើលទ្ធផលនៃកិច្ចប្រតិបត្តិការការពារសន្តិសុខ និងការអនុវត្តច្បាប់
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាននៃ **គ.ជ.ស.ស.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **គ.ជ.ស.ស.** ប្រគល់ជូន។

**មាត្រា១១.-**

នាយកដ្ឋានផ្គត់ផ្គង់ មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- គ្រប់គ្រងនិងអនុវត្តការងារភស្តុភារ ហិរញ្ញវត្ថុ និងអចលនទ្រព្យរបស់ **គ.ជ.ស.ស.**
- សម្របសម្រួលការងារភស្តុភារ សម្ភារៈបច្ចេកទេស សម្រាប់ទ្រទ្រង់កិច្ចប្រតិបត្តិការនិងការបំពេញបេសកកម្មនានារបស់ **គ.ជ.ស.ស.**
- ធ្វើផែនការសម្រាប់គ្រប់គ្រងនិងថែទាំសម្ភារៈបរិក្ខារ របស់សមត្ថកិច្ចដែលនៅក្រោមការទទួលខុសត្រូវរបស់ **គ.ជ.ស.ស.**
- ធ្វើការងារលទ្ធកម្ម
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **គ.ជ.ស.ស.** ប្រគល់ជូន។

**មាត្រា១២.-**

នាយកដ្ឋាននីតិកម្ម មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- សិក្សាស្រាវជ្រាវ អំពីច្បាប់ជាតិ និងអន្តរជាតិ
- ធ្វើការអប់រំនិងបញ្ជ្រាបការយល់ដឹងផ្នែកច្បាប់និងបទប្បញ្ញត្តិនានា ដល់កម្លាំងសមត្ថកិច្ចពាក់ព័ន្ធ ព្រមទាំងចូលរួមចំណែកក្នុងការពង្រីកការយល់ដឹងនេះ នៅក្នុងសហគមន៍ប្រជាពលរដ្ឋ
- រៀបចំសេចក្តីព្រាងច្បាប់និងបទប្បញ្ញត្តិទាំងឡាយណាដែលត្រូវការចាំបាច់ នៅក្នុងវិស័យសន្តិសុខលម្ហសមុទ្រ ដោយធ្វើយ៉ាងណាឱ្យច្បាប់របស់ប្រទេសជាតិឆ្លុះបញ្ចាំងជាមួយច្បាប់អន្តរជាតិ
- ធ្វើការងារផ្នែកច្បាប់នៅក្នុងករណីបទល្មើសសន្តិសុខលម្ហសមុទ្រ
- ធ្វើការងារក្នុងនាម **គ.ជ.ស.ស.** នៅក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងផ្នែកច្បាប់
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ស.ស.**
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការ **គ.ជ.ស.ស.** ប្រគល់ជូន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៤
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១០
ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ

**អង្គការលេខ របស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសន្តិសុខលម្ហសមុទ្រ**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ:៧៨៣ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ជូន នាយ-នាយរងនគរបាលជាតិ មន្ត្រីរាជការ និងសប្បុរសជន ដែលមានស្នាដៃល្អគុណបំណាច់ខ្ពស់ក្នុងការចូលរួមចំណែកជួយស្តារអភិវឌ្ឍន៍សង្គមជាតិលើគ្រប់វិស័យក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

**ក. <u>គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ ធិបឌិន្ទ :</u>**

| | | |
|---|---|---|
| ១. លោកស្រី | **ទីរក្ស ទិទ្ធិនី** | អនុប្រធានអធិការកិច្ចនៃអគ្គាធិការដ្ឋាន |
| ២. លោកឧត្តមសេនីយ៍ត្រី | **គឹម សម្បត្តិ** | អត្តលេខ ០៣៩៥ អនុប្រធានអធិការកិច្ចនៃអគ្គាធិការដ្ឋាន |
| ៣. លោកវរៈសេនីយ៍ឯក | **គួន ផល** | អត្តលេខ ០១៥០៦ នាយរងការិយាល័យនៃអគ្គាធិការដ្ឋាន |
| ៤. លោកវរៈសេនីយ៍ត្រី | **គូ សុផល** | អត្តលេខ ០៤៩៧៣ នាយរងការិយាល័យនៃអគ្គាធិការដ្ឋាន |
| ៥. លោកអនុសេនីយ៍ទោ | **សួរ ឫទ្ធី** | អត្តលេខ ៥៦៤៩៦ នាយរងផ្នែកនៃអគ្គាធិការដ្ឋាន |
| ៦. លោកអនុសេនីយ៍ទោ | **ផល ពៅ** | អត្តលេខ ៣៣៦០៩ នាយផ្នែកនាយកដ្ឋានអង្គរក្ស |
| ៧. លោក | **សោម សុផល** | សប្បុរសជន |
| ៨. លោក | **សោម សុគុសល** | សប្បុរសជន |

ខ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ សេនា :

១. លោកវរៈសេនីយ៍ទោ ឯក ចិន្តា អត្តលេខ ០២១៦៦ នាយការិយាល័យនៃអគ្គាធិការដ្ឋាន

២. លោកវរៈសេនីយ៍ទោ ហ៊ុយ សោភ័ណតារា អត្តលេខ ០២១៤៦ នាយការិយាល័យនៃអគ្គាធិការដ្ឋាន

៣. លោកវរៈសេនីយ៍ត្រី មាន ចាន់ធូ អត្តលេខ ១២៥៦៤ នាយរងការិយាល័យនៃអគ្គាធិការដ្ឋាន

៤. លោកវរៈសេនីយ៍ត្រី ទូ ឆាយ អត្តលេខ ០៤៩៥៣ នាយរងការយាល័យនៃអគ្គាធិការដ្ឋាន

៥. លោកអនុសេនីយ៍ឯក អាច ឫទ្ធិ អត្តលេខ ៣៧៣៦៣ នាយរងការិយាល័យនៃអគ្គាធិការដ្ឋាន

គ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ អស្សឫទ្ធិ :

១. លោក ឈា ឡាយហ៊ី ប្រធានការិយាល័យនៃអគ្គាធិការដ្ឋាន

២. លោក ប៉ៃ ធារាវង្ស អនុប្រធានការិយាល័យនៃអគ្គាធិការដ្ឋាន

៣. លោក ប៊ិន ឡាដា អនុប្រធានការិយាល័យនៃអគ្គាធិការដ្ឋាន

៤. លោកអនុសេនីយ៍ឯក ខៀវ សុខ អត្តលេខ ០៩៤៥៩ នាយរងការិយាល័យនៃអគ្គាធិការដ្ឋាន

៥. លោកអនុសេនីយ៍ឯក គូ សុផល អត្តលេខ ៥៦២៨២ នាយរងការិយាល័យនៃអគ្គាធិការដ្ឋាន

៦. លោកអនុសេនីយ៍ទោ គីម ខ្មៅ អត្តលេខ ៣៤៣៤៨ នាយរងផ្នែកប៉ុស្តអន្តរជាតិព្រលានយន្តហោះភ្នំពេញ

៧. លោកស្រី រិន ម៉ារីណា មន្ត្រីនៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល

៨. លោក វ៉ែន ពិសី នាយផ្នែកលេខាធិការដ្ឋាន នៃអគ្គាធិការដ្ឋាន

៩. លោក ឱុច ចន្ថា នាយរងផ្នែកលេខាធិកដ្ឋាន នៃអគ្គាធិការដ្ឋាន

១០. លោក អ៊ីវ ម៉ហេង នាយរងផ្នែកលេខាធិកដ្ឋាន នៃអគ្គាធិការដ្ឋាន

១១. លោក ឱុច ច័ន្ទរ៉ុង នាយរងផ្នែកលេខាធិកដ្ឋាន នៃអគ្គាធិការដ្ឋាន

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

### ស ម្រេ ច

**មាត្រា ១** ៖ ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជនចំនួន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សាលាបាលី សាលាឆាន់ កុដិ ស្រះទឹក និងសមិទ្ធផលនានា ស្ថិតក្នុងវត្តកំពង់ភ្នំ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

១-លោក **ប៉ែន ច័ន្ទដារិទ្ធ** សប្បុរសជននៅខេត្តកណ្តាល ថវិកាចំនួន ៦៧.០០០ដុល្លារ

២-លោក **ហ្វូត យាខខេខ** សប្បុរសជននៅខេត្តកណ្តាល ថវិកាចំនួន ៦៦.០០០ដុល្លារ

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល*** ៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៧៥៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

### ស ម្រេ ច

**មាត្រា ១** ៖ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **តាំង ហាក់យូ** សប្បុរសជននៅខេត្តកណ្តាល ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សាលាបាលី សាលាឆាន់ កុដិ ស្រះទឹក និងសមិទ្ធផលនានា ស្ថិតក្នុងវត្តកំពង់ភ្នំ ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល ចំណាយថវិកាអស់ចំនួន ១២.០០០ ដុល្លា ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល ៖***
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
*-ដូចមាត្រា១ និងមាត្រា២*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការតែងតាំងមន្ត្រីត្រួតពិនិត្យរដ្ឋអមប្រៃសណីយ៍កម្ពុជា

*********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦ / នស /៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១២ ,ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិស័យប្រៃសណីយ៍
- បានឃើញព្រះរាជក្រមលេខ ជស/ រកម /០៦៩៦ /០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រម លក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីស្តង់ការគណនីនៃសហគ្រាសសាធារណៈ

- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១០ ស្ដីពីការបង្កើតប្រៃសណីយ៍កម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានតែងតាំងលោក **សុខ ធី** បច្ចុប្បន្នអនុប្រធានការិយាល័យ នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមន្ត្រីត្រួតពិនិត្យរដ្ឋអមប្រៃសណីយ៍កម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាម៉ីខ្លួនត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០១០

<u>**កន្លែងទទួល:**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-ឯកសារ-កាលប្បវត្តិ

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូននាយក នាយករងអង្គការ WFP និងមន្ត្រីជាន់ខ្ពស់ ចំនួន០៣រូប ដែលបានសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការអនុវត្តកម្មវិធីការងារស្បៀងអាហារ ពិភពលោក **World Food Program (WFP)** ដោយបានផ្តល់ជាអង្ករប្រមាណ ១០.០០០ តោន សម្រាប់អនុវត្តការងារស្បៀងពលកម្ម និងចែកជូនប្រជាពលរដ្ឋក្រីក្រ នៅតាមឃុំគោលដៅ តំបន់ដាច់ស្រយាល គិតជាទឹកប្រាក់ ប្រមាណ ៨.២៦០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ:**

-លោក **Jean Pierre de Margerie** នាយកអង្គការ

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា:**

-លោក **Kenneth R.crossley** នាយករងអង្គការ

**គ-មេដាយសហមេត្រី ថ្នាក់ អស្សប្ញទ្ធិ:**

-លោក **Joachim Groder** មន្ត្រីជាន់ខ្ពស់

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។ ស HSR

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៨៨ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនសមាជិកក្រុមការងារ ចំនួន០៤រូប ដែលបានចូលរួមចំណែកក្នុងការកសាងព្រះវិហារ កុដិ សាលាពុទ្ធិកសិក្សា របង ដងទង់ ស្រះទឹក សាលាបាលី សាលាឆាន់ ឧបដ្ឋានសាលា ស្ពាន ថ្នល់ ខ្លោងទ្វារ ម៉ាស៊ីនភ្លើង និង សមិទ្ធផលនានាជាច្រើនទៀត ស្ថិតនៅវត្តទេពនិម្មិត សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម ៖

១-លោក កែវ ឧត្តី

២-លោក ឌុយ ខេងពិចិត្រ

៣-អ្នកស្រី ប៉ែន ស៊ីចាន់ថុន

៤-អ្នកស្រី សេង ស៊ីណា

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ

### សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៩រូប ដែលបានចូលរួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង បរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការកសាងព្រះវិហារ កុដិ សាលាពុទ្ធិកសិក្សា របង ដងទង់ ស្រះទឹក សាលាបាលី សាលាឆាន់ ឧបដ្ឋានសាលា ស្ពាន ថ្នល់ ខ្លោងទ្វារ ម៉ាស៊ីនភ្លើង និង សមិទ្ធផលនានាជាច្រើនទៀត ស្ថិតនៅវត្តទេពនិម្មិត សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទៈ**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | ស៊ឿន | សាន្ត | បច្ច័យ ចំនួន ៨២.៣២០ ដុល្លារ |
| ២-ព្រះតេជគុណ | ឃុន | សុយៀង | បច្ច័យ ចំនួន ៨១.៨៥០ ដុល្លារ |
| ៣-ព្រះតេជគុណ | សំរិត | ណាំង | បច្ច័យ ចំនួន ៨០.៤៣០ ដុល្លារ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា:**

| | | | |
|---|---|---|---|
| ១-លោក | ជា | សំអឿន | រួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន |
| ២-លោក | ស្វរ | វិបុល | រួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន |
| ៣-លោក | គន់ | សារ៉ាន់ | រួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ:**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | សែម | សុវណ្ណ | បច្ច័យ ចំនួន ២៨.៣១០ ដុល្លារ |
| ២-ព្រះតេជគុណ | ឡឿន | កុសល | បច្ច័យ ចំនួន ២៧.២៣០ ដុល្លារ |
| ៣-ព្រះតេជគុណ | គិន | ចន្ថា | បច្ច័យ ចំនួន ២៦.២១០ ដុល្លារ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៩០.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ

**សម្រេច**

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ប្រគេនព្រះសង្ឃ ចំនួន០៣អង្គ ដែលបានចូលរួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និង បរិច្ចាគធនធានផ្ទាល់ខ្លួន ក្នុងការកសាងព្រះវិហារ កុដិ សាលាពុទ្ធិកសិក្សា របង ដងទង់ ស្រះទឹក សាលាបាលី សាលាឆាន់ ឧបដ្ឋានសាលា ស្តូប ថ្នល់ ខ្លោងទ្វារ ម៉ាស៊ីនភ្លើង និងសមិទ្ធផលនានាជាច្រើនទៀត ស្ថិតនៅវត្តទេពនិម្មិត សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដូចមានរាយព្រះនាមខាងក្រោម ៖

១-ព្រះតេជគុណ សៀង សុខ បច្ច័យ ចំនួន ១១.៨៣៥ ដុល្លារ
២-ព្រះតេជគុណ ណិប រ៉ាន បច្ច័យ ចំនួន ១១.៦១០ ដុល្លារ
៣-ព្រះតេជគុណ ឡាំ អ៊ិត បច្ច័យ ចំនួន ១១.៤២៣ ដុល្លារ

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល នៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ៧៩១ .អនក្រ .បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

## សម្រេច

### មាត្រា១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូននាយនគរបាល នាយអាវុធហត្ថ ព្រមទាំងមន្ត្រីរាជការ ចំនួន ០៤រូប ដែលបានចូលរួមចំណែកក្នុងការកសាង អភិវឌ្ឍន៍សមិទ្ធផលនានាលើគ្រប់វិស័យ ព្រមទាំងបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ ប្រាសាទ របងវត្ត ខ្លោងទ្វារ ឧបដ្ឋានសាលា នៅក្នុងវត្តព្រៃបាស្រី ស្ថិតនៅឃុំជើកពត ស្រុកព្រះស្តេច ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

១-លោកអនុសេនីយ៍ឯក ហួន លន់ អត្តលេខ ០៩៩១៦ នាយរងការិ.នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ

២-លោកអនុសេនីយ៍ទោ នូ សាន អត្តលេខ ១៩៦៦១៧ នាយការិ.នៃកងរាជអាវុធហត្ថខេត្តព្រៃវែង

៣-លោក ឆា ចេស្តា គ្រូបង្រៀននៅសាលាបឋមសិក្សាព្រៃវែងក្រុង

៤-លោកស្រី ឆា សូរិយា គ្រូបង្រៀននៅសាលាបឋមសិក្សាព្រៃវែងក្រុង

### មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផល។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨២ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ព្រមទាំងមន្ត្រីរាជការ ចំនួន០៥រូប ដែលបានចូលរួមចំណែកក្នុងការកសាង អភិវឌ្ឍន៍សមិទ្ធផលនានាលើគ្រប់វិស័យ ព្រមទាំងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងព្រះវិហារ ប្រាសាទ របងវត្ត ខ្លោងទ្វារ ឧបដ្ឋានសាលា នៅក្នុងវត្តព្រៃបាស្រី ស្ថិតនៅឃុំជើកំពឹត ស្រុកព្រះស្ដេច ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក ម៉ិច សុខ | សមាជិកក្រុមប្រឹក្សាស្រុកព្រះស្ដេច | ថវិកា១២.៩៣០ ដុល្លារ |
| ២-លោក ជឹម សុខ | សប្បុរសជននៅភូមិកំពង់សឹង ឃុំកំពង់សឹង | ថវិកា១២.៧៧០ ដុល្លារ |
| ៣-លោកអាចារ្យ គីម សុន | សប្បុរសជននៅភូមិទួលលាន ឃុំជើកំពក | ថវិកា ១០.១៩២ ដុល្លារ |
| ៤-លោកអាចារ្យ ណោច ពុំ | សប្បុរសជននៅភូមិកំពង់បាស្រី ឃុំជើកំពក | ថវិកា ១០.៤០០ ដុល្លារ |
| ៥-លោកអាចារ្យ អ៊ុក ខន្ធ | សប្បុរសជននៅភ្នំពេញ | ថវិកា ១០.៤០០ ដុល្លារ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានល[illegible]

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៣ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយមាសការងារ ជូននគរបាលនិងមន្ត្រីរាជការ ចំនួន១០រូប ដែលមានស្នាដៃល្អ ខិតខំយកអស់កំលាំងកាយចិត្តបំពេញការងារ ភារកិច្ច ចូលរួមចំណែកកសាងអភិវឌ្ឍន៍សមិទ្ធផលផ្សេងៗ ទាំងផ្នែករាណាចក្រ និង ពុទ្ធចក្រ នៅតាមបណ្តាស្រុក ទូទាំងខេត្ត ធ្វើអោយវិស័យនានានៅក្នុងខេត្តព្រៃវែង មានការរីកចំរើនគួរអោយកោតសរសើរ ដូចមានរាយនាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១-លោកអនុសេនីយ៍ឯក | ម៉ិល | សិរី | ០៨៧៣១ | អនុប្រធានការិ. នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ២-លោកអនុសេនីយ៍ឯក | ផាត់ | សុផារី | ០១១១៩៨ | ប្រធានផ្នែក នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៣-លោកអនុសេនីយ៍ទោ | ម៉ុំ | សេង | ០១៣៦៨៨ | នាយផ្នែកស្ថិតិ និងអត្តសញ្ញាណប័ណ្ណនគរបាលក្រុងព្រៃវែង |
| ៤-លោកអនុសេនីយ៍ត្រី | យិន | សំណាង | ៣៤៧៦០ | មន្ត្រីនគរបាលចរាចរណ៍ នៃស្នងការដ្ឋាននគរបាល ខេត្តព្រៃវែង |
| ៥-លោកអនុសេនីយ៍ត្រី | ផន | សុគុល | ៣៤៦៣៨ | នាយរងផ្នែកសណ្តាប់ធ្នាប់នគរបាលស្រុកពារាំង |
| ៦-លោកព្រឹទ្ធបាលឯក | គួយ | វណ្ណា | ៥៧៣៩៦ | មន្ត្រីនគរបាលការិ.សេដ្ឋកិច្ចរាជធានីភ្នំពេញ |
| ៧-លោកព្រឹទ្ធបាលទោ | ចិក | ពៅ | ៥០៩៦៣ | នគរបាលអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៨-លោកពលបាលឯក | ទិន | ម៉េង | ៥០៨៧០ | មន្ត្រីនគរបាលចរាចរណ៍ នៃស្នងការដ្ឋាននគរបាល ខេត្តព្រៃវែង |
| ៩-លោក | ផ៊ុន | សុផាត | | មន្ត្រីធនាគារជាតិនៃកម្ពុជា បំរើការងារសាខាខេត្តព្រៃវែង |
| ១០-លោក | អាន | សុផល | | មន្ត្រីក្រមការសាលាខេត្តព្រៃវែង |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ ២០១០

ហត្ថលេខា និងត្រា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៩៤ ,អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់ មេដាយសុវត្ថារា តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នគរបាលនិងកងរាជអាវុធហត្ថ ចំនួន១៣រូប ដែលមានស្នាដៃល្អ ខិតខំយកអស់កំលាំងកាយចិត្តបំពេញការងារ ភារកិច្ច ចូលរួមចំណែកកសាង អភិវឌ្ឍន៍សមិទ្ធផលផ្សេងៗ ទាំងផ្នែកអាណាចក្រ និង ពុទ្ធចក្រ នៅតាមបណ្តាស្រុក ទូទាំងខេត្ត ធ្វើអោយវិស័យនានានៅក្នុងខេត្តព្រៃវែង មានការរីកចំរើនគួរអោយកោតសរសើរ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទៈ**

| | | | | |
|---|---|---|---|---|
| ១-លោកវរសេនីយ៍ឯក | ញៀម | សុគី | ០១៧៩១ | ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ២-លោកវរសេនីយ៍ឯក | ទិន់ | សារឿន | ០២២០៩ | ស្នងការរងនៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៣-លោកវរសេនីយ៍ឯក | សោ | សាវឿន | ០០២៨៩៩ | មេបញ្ជាការរងកងរាជអាវុធហត្ថ ខេត្តព្រៃវែង |
| ៤-លោកវរសេនីយ៍ទោ | អ៊ី | សំអុល | ០៣២៧៨ | ប្រធានការិ.នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៥-លោកវរសេនីយ៍ទោ | ពៅ | ជីវី | ០១២៩៨៨ | ប្រធានការិ.នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៦-លោកវរសេនីយ៍ទោ | អ៊ឹម | សុផល | ០១២៩៨៣ | ប្រធានការិ.នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង |
| ៧-លោកវរសេនីយ៍ត្រី | ឃួន | ទិន់ថេន | ០១២២២៦ | មេបញ្ជាការវរៈការពារព្រំដែន ៦០៧ ខេត្តព្រៃវែង |
| ៨-លោកវរសេនីយ៍ត្រី | កែវ | ជា | ១២៤៣៩ | នាយប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិបន្ទាយចក្រី |
| ៩-លោក | ជិន | តារា | | នាយរងផ្នែករដ្ឋបាលព្រៃឈើ ព្រៃវែង |
| ១០-លោក | ហ៊ុន | លាន | ១២៤ | អនុប្រធានសាខាកាំកុងត្រូលប្រចាំខេត្តព្រៃវែង |

១១-លោកអនុសេនីយ៍ទោ ឈាង សារិទ្ធ ០១៦៣៨២ ប្រធានប៉ុស្តិ៍នគរបាលការពារព្រំដែនវរៈ៦០៧ បន្ទាយចក្រី

១២-លោកអនុសេនីយ៍ទោ អេង លី ០១២៤១៦ ប្រធាននគរបាលផ្តល់ទិដ្ឋាការច្រកទ្វារអន្តរជាតិ បន្ទាយចក្រី

ខ-មេដាយសុវត្ថារា ថ្នាក់ សេនា:

-លោកអនុសេនីយ៍ទោ ឃុន មុន្នីរាត ៣៦៥៨៣ នគរបាលវរៈការពារព្រំដែន ខេត្តព្រៃវែង

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៣៩ . សសរ**

# សេចក្តីសម្រេច

**ស្តីពី**

**ការផ្ទេរក្របខ័ណ្ឌ នាយទាហាន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៨ ស្តីពីការកែសំរួលរចនាសម្ព័ន្ធនិងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**ប្រការ១ :** ត្រូវបានផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន អនុសេនីយ៍ឯក **ចាប ឌីណា** អត្តលេខ ០២១២៧២ កងឯកភាព បញ្ជាការដ្ឋានកងទ័ពជើងអាកាស អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នទៅបំរើការងារ ក្នុងក្របខ័ណ្ឌ មន្ត្រីរាជការស៊ីវិល នៃក្រសួងមហាផ្ទៃ ។

**ប្រការ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធនិងបណ្តាសមាសភាពដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៧១៧ ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញប្រកាសលេខ ១០៨៩ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៦.១១.២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន សាន់ វែល ស៊ូ ចុះថ្ងៃទី២៥.០៦.២០១០

## ស ម្រេ ច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន សាន់ វែល ស៊ូ តំណាងដោយ លោកស្រី CHEN, LI-LAN សញ្ជាតិចិន (តៃវ៉ាន់) អាយុ៨៦ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 131206348 ចុះថ្ងៃទី២១.០២.២០០១ មានអាសយដ្ឋានបច្ចុប្បន្ន៖405, Lien Tsun Le, Lien Tsun Rd., Feng Yuan, Taichuring Hsien, Taiwan. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| ស្បែកជើង | ៣២៤០ |

-ផ្លាកឈ្មោះរោងចក្រ ៖" *សាន់ វែល ស៊ូ (SUN WELL SHOES CO., LTD.)*"



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១. ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ទីតាំងរោងចក្រ ៖ *" ផ្លូវចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១**: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២**: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣**: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤**: ប្រកាសលេខ ១០៨៩ ឧរថ.កឧ.ប្រក និង វិញ្ញាបនបត្រលេខ ៩៣ ឧរថ.កឧ.បរ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន សាន់ វែល ស៊ូ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥**: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦**: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ ...១១៣...ឧរថ.កឧ.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញប្រកាសលេខ ០២២ ឧរថ.កឧ.ប្រក ចុះថ្ងៃទី០៩.០១.២០០៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ឌឹ វ៉ន (ខេមបូឌា) អ៊ិនជាសស្ទ្រី ចុះថ្ងៃទី០៧.០៧.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ឌឹ វ៉ន (ខេមបូឌា) អ៊ិនជាសស្ទ្រី តំណាងដោយ លោក CHEN JIM KO-KANG សញ្ជាតិអូស្ត្រាលី អាយុ២៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ L4547661 ចុះថ្ងៃទី០៧.១១.២០០២ មានអាសយដ្ឋានបច្ចុប្បន្ន៖ 9 WANRANDOO, St. GORDON NSW 2072, AUSTRALIA ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| កាត់ដេរសម្លៀកបំពាក់ | ៣២២០ |

-ផ្លាកឈ្មោះរោងចក្រ ៖ *" ឌឹ វ៉ន (ខេមបូឌា) អ៊ិនជាសស្ទ្រី (THE ONE (CAMBODIA) INDUSTRIES CO., LTD.)"*



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ទីតាំងរោងចក្រ ៖ *"ប្លុកសួនឧស្សាហកម្មពោធិ៍ចិនតុង ផ្លូវលំ ភូមិព្រៃទា សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងលើគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១**: លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២**: ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣**: -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានទាន់ពេលវេលា អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤**: ប្រកាសលេខ០២២ ឧរថ.កឧ.ប្រក និងវិញ្ញាបនបត្របង្កើតរោងចក្រលេខ ០០៤ ឧរថ.កឧ.បរ ចុះថ្ងៃទី០៩.០១.២០០៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ របស់ក្រុមហ៊ុន ឌី វ៉ន (ខេមបូឌា) អ៊ិនដាសស្ទ្រី ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥**: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦**: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ_សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៦១៤ ឧរ៉ថ.កន.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០

# ប្រកាសបង្កើតរោងចក្រ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យច្បាប់ស្តីពី ការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញលិខិតលេខ ៧២០ /០៨ ក.អ.ក ចុះថ្ងៃទី០៦.០៣.២០០៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន អ៊ី-យាន អ៊ិនធើណេសិនណល ខប ចុះថ្ងៃទី០១.០៧.២០១០

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន អ៊ី-យាន អ៊ិនធើណេសិនណល ខប តំណាងដោយ លោក CHENG, DI-YUAN សញ្ជាតិចិន(តៃវ៉ាន់) អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 300093026 ចុះថ្ងៃទី១៥.០១.២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ No 30, St., Xi Man, Shang 352, Tai Nan, Taiwan. ជាម្ចាស់រោងចក្រ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម ៖

| -ឈ្មោះផលិតផល | លេខចុះបញ្ជីផលិតផល ISIC Code |
|---|---|
| សម្លៀកបំពាក់ (កាត់ដេរ និងប៉ាក់) | ៣២២០ ១៨១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ទូរស័ព្ទ (៨៥៥)-២៣-២១១១៤១, ទូរសារ : ៨៥៥-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax : 855-23-428263

-ផ្លាកឈ្មោះរោងចក្រ ៖ *" អ៊ី-យាន អ៊ិនធើណេសិនណល ខប (E-YUAN INTERNATIONAL CORP.)"*

-ទីតាំងរោងចក្រ ៖ *"ផ្ទះលេខ ៧៤៨-៧៥០ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ "*

**ប្រការ២:** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន ។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ៣:** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ។

**ប្រការ៥:** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ ។

**ប្រការ៦:** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង

និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ ។

**ប្រការ៧:** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅអគ្គនាយកដ្ឋានឧស្សាហកម្ម ។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨:** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩:** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ ។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។

**ប្រការ១០:** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្មស្របតាម បទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល ។

**ប្រការ១១:** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ ។

**ប្រការ១២:** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ ។

**ប្រការ១៣:** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬ ករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ ។

**ប្រការ១៤:** ប្រកាសលេខ ៩៧៤ ឧរថ.កឧ.ប្រក និងវិញ្ញាបនបត្របង្កើតរោងចក្រ លេខ០៨២ ឧរថ.កឧ.បរ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបង្កើតរោងចក្រ កាត់ដេរ និងប៉ាក់សម្លៀកបំពាក់ របស់ក្រុមហ៊ុន អ៊ី-យាន អ៊ិនធើណេសិនណល ខប ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៥:** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន ។

**ប្រការ១៦:** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

**ចម្លងជូន:**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខៈ៣៥៣...ប្រ.តសក/គណក

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ឝ៍៣ ឆ្នាំ ២០១០

# ប្រកាស

## ស្តីពី

## តួនាទី និងភារកិច្ច របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញ អនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការរៀបចំបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- យោងតាមការចាំបាច់

## សម្រេច

ប្រការ១ ៖ ត្រូវបានរៀបចំតួនាទីរបស់ គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានសមាសភាពដូចខាងក្រោម ៖

១. ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធាន

២. *ឯកឧត្តម ឯម សំអាន* រដ្ឋលេខាធិការក្រសួងមហាផ្ទៃ *អនុប្រធាន*
៣. *ឯកឧត្តម លឹម ស៊ីដេនីន* រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន *សមាជិកអចិន្ត្រៃយ៍*
៤. *ឯកឧត្តម ជា ប៉េងឈាង* រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *សមាជិក*
៥. *ឧត្តមសេនីយ៍ទោ ម៉ែន សុផុន* អនុប្រធាន នាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការនគរបាលជាតិ *សមាជិក*
៦. *ឧត្តមសេនីយ៍ទោ នន្ទ សុខា* មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស *សមាជិក*
៧. *អភិបាលរាជធានី-ខេត្ត* *សមាជិក*

ប្រការ២ : គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំ និងដាក់ចេញវិធានការទប់ស្កាត់រាល់សកម្មភាពដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំ និងដាក់ចេញនូវគោលការណ៍អនុវត្តការត្រួតពិនិត្យយានយន្តដឹកជញ្ជូន លើសទម្ងន់កម្រិតកំណត់ នៅលើបណ្តាញផ្លូវជាតិនៃព្រះរាជាណាចក្រកម្ពុជា ។
- សម្របសម្រួលតាមដាន និងត្រួតពិនិត្យការអនុវត្តន៍ការងារ របស់គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ។
- រាយការណ៍ជូនរាជរដ្ឋាភិបាល នូវសកម្មភាពត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់របស់រាជរដ្ឋាភិបាល ។

ប្រការ៣ : ត្រូវបានរៀបចំតួនាទីរបស់គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានសមាសភាពដូចខាងក្រោម ៖

១. *ឯកឧត្តម លឹម ស៊ីដេនីន* តំណាងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន *ប្រធាន*
២. *ឯកឧត្តម គីម បូរី* អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការក្រសួង ស.ក.ដ *អនុប្រធាន*
៣. *លោក ចាន់ តារា* តំណាងអគ្គនាយកដ្ឋានដឹកជញ្ជូនក្រសួងស.ក.ដ *សមាជិក*
៤. *ឧត្តមសេនីយ៍ត្រី ហ៊ឹម យ៉ាន* តំណាងអគ្គស្នងការនគរបាលជាតិ *សមាជិក*
៥. *វរៈសេនីយ៍ទោ ឆែម សុខឿន* តំណាងបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស *សមាជិក*
៦. *លោក ជា គឹមគុង* តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ *សមាជិក*
៧. តំណាងសាលារាជធានី-ខេត្ត *សមាជិក*
៨. តំណាងមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត *សមាជិក*

ប្រការ៤ : គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ នៃគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំសេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។
- រៀបចំសមាសភាពរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំកំណត់ទីតាំងរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដើម្បីដាក់ក្នុងកញ្ចប់ថវិកាក្រសួងសាធារណការ និងដឹកជញ្ជូន
- សម្របសម្រួល និងជំរុញសកម្មភាពត្រួតពិនិត្យរបស់អង្គភាពត្រួតពិនិត្យ និងស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- កំណត់កម្មវិធីការងាររបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បែងចែកតួនាទី និងភារកិច្ចរបស់អង្គភាពស្ថានីយថ្លឹងយានយន្តលើសទម្ងន់កម្រិតកំណត់
- ទំនាក់ទំនង និងសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ណែនាំការផាកពិន័យតាមកំហុសជាក់ស្តែង ដោយអនុលោមតាមមាត្រា ៨៤ នៃច្បាប់ចរាចរណ៍ផ្លូវគោក និង បទបញ្ញត្តិផ្សេងៗទៀតជាធរមាន
- អាចប្រើប្រាស់មន្ត្រីជំនាញតាមសមត្ថភាពរៀងៗខ្លួន តាមពេលវេលា និងទំហំការងារចាំបាច់
- បង្កើតក្រុមត្រួតពិនិត្យចល័តពិសេសសម្រាប់បេសកកម្មមួយរយៈ ដើម្បីធ្វើការត្រួតពិនិត្យយានយន្តដឹកជញ្ជូន លើសទម្ងន់កម្រិតកំណត់ នៅតាមបណ្តាញផ្លូវដែលពុំមានស្ថានីយថ្លឹងយានយន្ត
- គ្រប់គ្រងប្រាក់ដែលបានមកពីការផាកពិន័យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- ត្រូវកំណត់បទបញ្ជាផ្ទៃក្នុងសំរាប់អនុវត្តការងារឲ្យមានប្រសិទ្ធភាព
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ប្រគល់ជូន ។

ប្រការ៥ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៦ : នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយក នៃអគ្គនាយកដ្ឋានសាធារណការ អគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន អគ្គាធិការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូច **ប្រការ១** និង **ប្រការ៣** ត្រូវទទួលអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ត្រាំ អ៊ីវទឹក**

**កន្លែងទទួលៈ**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការពារជាតិ (កងរាជអាវុធហត្ថលើផ្ទៃប្រទេស)
- ក្រសួងមហាផ្ទៃ
- សាលារាជធានី-ខេត្ត
- មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី-ខេត្ត
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ